**អង្គការសហប្រជាជាតិ** E

**ក្រុមប្រឹក្សាសេដ្ឋកិច្ច**
**និងសង្គមកិច្ច**

ចែកចាយទូទៅ
E/CN.4/2006/41/Add.3
ថ្ងៃទី២១ ខែមីនា ឆ្នាំ ២០០៦
អត្ថបទដើម: អង់គ្លេស

គណៈកម្មការសិទ្ធិមនុស្ស
សម័យប្រជុំលើកទី៦២
ចំណុចទី១០ នៃរបៀបវារៈបណ្ដោះអាសន្ន

# សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

របាយការណ៍របស់លោក **មីលូន កូថារី** អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពសមរម្យ

របាយការណ៍បន្ថែម

បេសកកម្មមកកាន់ប្រទេសកម្ពុជា * **

* អត្ថបទសង្ខេបត្រូវបានផ្សព្វផ្សាយគ្រប់ភាសាទាំងអស់ ។ របាយការណ៍ទាំងមូល ដែលបានភ្ជាប់ឧបសម្ព័ន្ធទៅនឹងអត្ថបទសង្ខេបត្រូវបានផ្សព្វផ្សាយតែភាសាអង់គ្លេសប៉ុណ្ណោះ ។

** អនុលោមតាមកថាខ័ណ្ឌទី៨ ផ្នែក ខ នៃសេចក្ដីសំរេចចិត្តលេខ ៥៣/២០៨ ការដាក់ស្នើចុងក្រោយ នៃរបាយការណ៍នេះ គឺអាស្រ័យដោយសេចក្ដីត្រូវការ ដើម្បីឆ្លុះបញ្ចាំងពីការវិវត្តន៍ថ្មីៗបំផុត ។

GE.06-11937 (E) 300306

# ឧបសម្ព័ន្ធ

## របាយការណ៍របស់លោក **មីលូន កូតារី** អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ ពាក់ព័ន្ធនឹងបេសកកម្មរបស់លោកមកកាន់ប្រទេសកម្ពុជា

## (ថ្ងៃទី២២ ខែសីហា ដល់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៥)

## មាតិកា


| | *កថាខ័ណ្ឌ* | *ទំព័រ* |
|---|---|---|
| សេចក្តីផ្តើម | ១ - ១០ | ៦ |
| **I- ក្របខ័ណ្ឌនៃនិយាមជាតិ និងអន្តរជាតិសំរាប់សិទ្ធិមានលំនៅដ្ឋានសមរម្យនៅក្នុងប្រទេសកម្ពុជា ជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ** | ១១- ២៥ | ៩ |
| ក- កាតព្វកិច្ចនៃរដ្ឋាភិបាលកម្ពុជា ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ | ១១ | ៩ |
| ខ-សិទ្ធិមានលំនៅដ្ឋានសមរម្យ និងអង្គការសហប្រជាជាតិនៅកម្ពុជា | ១២ -១៥ | ១០ |
| គ- រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ និងច្បាប់ភូមិបាល ឆ្នាំ២០០១ | ១៦ -២៥ | ១១ |
| **II- ស្ថានភាពខាងលំនៅដ្ឋាន : ទិដ្ឋភាពរួម** | ២៦ -៦០ | ១៤ |
| ក- ការដោះដូរដីធ្លី ឬ " ការលក់ដូរដី " | ៣០ - ៤៣ | ១៦ |
| ១- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | ៣៧ -៣៩ | ១៩ |
| ២- មន្ទីរពេទ្យព្រះមុន្នីវង្ស | ៤០ - ៤៣ | ២០ |
| ខ- ការបណ្តេញចេញដោយបង្ខំ | ៤៤ - ៥៥ | ២២ |
| ១- កោះពេជ្រ | ៥០ - ៥៣ | ២៣ |
| ២- ក្បាលស្ពាន | ៥៤ - ៥៥ | ២៦ |

| | | |
|---|---|---|
| គ- ភ្នំពេញ (២០០០-២០០៥ ) | ៥៦ - ៦០ | ២៧ |
| **III-** បញ្ហានៃការព្រួយបារម្ភជាពិសេស | ៦១ - ៧៩ | ៣០ |
| ក-និន្នាការចំបងៗ | ៦១ | ៣០ |
| ខ- កររិតជីវភាពក្រីក្រ | ៦២ -៦៦ | ៣២ |
| គ- ជនជាតិដើមភាគតិច | ៦៧ - ៧១ | ៣៤ |
| ឃ-ស្ត្រី | ៧២ - ៧៩ | ៣៦ |
| **IV-** កំណត់សំគាល់សន្និដ្ឋាន និងអនុសាសន៏ផ្សេងៗ | ៨០ - ៨៣ | ៣៩ |

## សេចក្តីសង្ខេប

អ្នករាយការណ៍ពិសេសសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុញ្ញាតដល់បេសក-កម្មរបស់លោកមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី២២ ខែសីហា ដល់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៥ ហើយក៏សូមស្វាគមន៍ដល់បំណងប្រាថ្នារបស់ខ្លួន ដែលផ្តល់ការយកចិត្តទុកដាក់ចំពោះសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានជីវភាពរស់នៅសមរម្យ។ គោលបំណងនៃបេសកកម្មនេះគឺដើម្បីពិនិត្យអំពីស្ថានភាពនៃការទទួលបានសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានជីវភាពរស់នៅសមរម្យ ដោយរួមទាំងសេវាពាក់ព័ន្ធនានា ដូចជា ទឹក និងអនាម័យ គោលនយោបាយសាធារណៈស្តីពីការតាំងទីលំនៅថ្មី ក៏ដូចជាអំពីទិដ្ឋភាពខាងយេនឌ័រនៃសិទ្ធិមានលំនៅដ្ឋានសមរម្យ និងច្បាប់នានាដែលពាក់ព័ន្ធដល់ការការពារសិទ្ធិមនុស្សទាក់ទងនិងអាណត្តិរបស់លោក។

បេសកកម្មនេះ គឺជាការបំពេញបន្ថែមទៅលើការងារកន្លងមកស្តីពីបញ្ហានានាទាក់ទងនឹងលំនៅដ្ឋាន ដោយការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា(OHCHR/Cambodia) និងដោយតំណាងពិសេសនានា នៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា។ បេសកកម្មនេះក៏ជាការបំពេញបន្ថែមផងដែរទៅលើទស្សនកិច្ចសិក្សាស្រាវជ្រាវកន្លងមកនៅប្រទេសកម្ពុជាក្នុងខែតុលា ឆ្នាំ២០០៤ ដែលនៅក្នុងអំឡុងពេលនោះ អ្នករាយការណ៍ពិសេសបានចូលរួមក្នុងទិវាលំនៅដ្ឋានពិភពលោក (World Habitat Day) កាលពីថ្ងៃទី៤ ខែតុលា ដោយមានការអញ្ជើញពីសាលាក្រុងភ្នំពេញ។

អ្នករាយការណ៍ពិសេសបានធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា នៅក្នុងខណៈពេលដែលប្រទេសនេះ កំពុងប្រឈមមុខតស៊ូយ៉ាងខ្លាំងក្លាក្នុងការបង្កើតស្ថាប័ននានាដែលមានលក្ខណៈប្រជាធិបតេយ្យ ក្រោមនីតិរដ្ឋ។ នៅក្នុងពេលបំពេញបេសកកម្មរបស់លោក អ្នករាយការណ៍ពិសេសបានសំគាល់ឃើញមានការខកខានក្នុងការអនុវត្តន៍ច្បាប់ភូមិបាលឆ្នាំ២០០១ និងការមិនគោរពរដ្ឋធម្មនុញ្ញនៃប្រទេសនេះ ដែលជាបុព្វហេតុដ៏ចំបងនៃបញ្ហា និងករណីជាក់លាក់ទាំងឡាយ ដែលលោកបានផ្តោតការយកចិត្តទុកដាក់ ដូចជា " ការលក់ដូរដី " និងការបណ្តេញដោយបង្ខំ។ ការមិនបានពង្រឹងការអនុវត្តន៍ច្បាប់ភូមិបាល ដែលទាមទារផងដែរនូវការ

អនុម័តអនុក្រឹត្យសំខាន់ៗមួយចំនួន ដើម្បីជំរុញការអនុវត្តន៍ច្បាប់ភូមិបាលឱ្យបានពេញលេញ បានធ្វើឱ្យខូចដល់ការទទួលបានសិទ្ធិមានលំនៅដ្ឋានសមរម្យនៃប្រជាពលរដ្ឋរាប់ពាន់គ្រួសារដែលរស់នៅទីក្រុង និងនៅតំបន់ជនបទ ក៏ដូចជាការគ្មានគោលនយោបាយជាតិ និងច្បាប់ស្តីពីលំនៅដ្ឋាន ដែលគិតគូយ៉ាងត្រឹមត្រូវអំពីសិទ្ធិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រនៅទីក្រុង និងនៅតំបន់ជនបទ ដែលពួកគេមិនមានលំនៅដ្ឋានសមរម្យ និងមធ្យោបាយផ្សេងៗដើម្បីធានាដល់ការទទួលបានសិទ្ធិនេះ។

ទោះជាយ៉ាងណាក៏ដោយ អ្នករាយការណ៍ពិសេសមានការពេញចិត្តចំពោះការផ្តួចផ្តើមគំនិតរបស់អង្គការក្រៅរដ្ឋាភិបាល និងសាលាក្រុងភ្នំពេញ ជាអាទិ៍ " សេចក្តីប្រកាសស្តីពីគោលការណ៍សំរាប់ការអនុវត្តន៍ដែលប្រសើរបំផុតក្នុងការអភិវឌ្ឍន៍ផ្នែកលំនៅដ្ឋាន និងការជួយដល់ប្រជាពលរដ្ឋក្រីក្រនៅក្នុងប្រទេសកម្ពុជា : ការលើកកំពស់គោលដៅអភិវឌ្ឍន៍ទីក្រុងផ្អែកលើសិទ្ធិជាមូលដ្ឋាន "(ថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៥)។ លោកក៏មានការពេញចិត្តផងដែរ ចំពោះការងារសាលាក្រុងភ្នំពេញជាមួយប្រជាពលរដ្ឋក្រីក្រនៅទីក្រុង ក៏ដូចជាការបង្កើតមុខតំណែងមន្ត្រីសិទ្ធិមានលំនៅដ្ឋានក្រុង និងចំពោះការខិតខំប្រឹងប្រែងធ្វើផែនការមេសំរាប់ការអភិវឌ្ឍន៍ និងការអនុវត្តន៍គោលដៅអភិវឌ្ឍន៍សហសវត្ស។ បន្ទាប់ពីដំណើរទស្សនកិច្ចរបស់លោក អ្នករាយការណ៍ពិសេសក៏មានក្តីសោមនស្សរីករាយផងដែរ ដោយសំគាល់ឃើញថា រដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៥។

ប៉ុន្តែជាទូទៅ អ្នករាយការណ៍ពិសេសមានការព្រួយបារម្ភជាខ្លាំង ចំពោះសភាពការណ៍ខាងលំនៅដ្ឋាននៅទូទាំងប្រទេសកម្ពុជា។ លោកបានស្នើយ៉ាងទទូចដល់រដ្ឋាភិបាលសូមឱ្យចាត់វិធានការគ្រប់បែបយ៉ាង ដើម្បីធានាសិទ្ធិខាងលំនៅដ្ឋានដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ស្របទៅតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន។

# សេចក្តីផ្តើម

១.  របាយការណ៍នេះត្រូវបានដាក់ជូនស្របតាមសេចក្តីសំរេចចិត្តលេខ២០០៤/២១ នៃគណៈកម្មការសិទ្ធិមនុស្ស។ ដោយមានការអញ្ជើញពីរាជរដ្ឋាភិបាលកម្ពុជា អ្នករាយការណ៍ពិសេសខាងសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធមានជីវភាពរស់នៅសមរម្យ បានបំពេញបេសកកម្មមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃ ទី២២ ខែ សីហា ដល់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៥។

២. អ្នករាយការណ៍ពិសេសបានជួបជាមួយមន្ត្រីជាន់ខ្ពស់មួយចំនួន នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងកិច្ចការនារី គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សាលាក្រុងភ្នំពេញ និងអាជ្ញាធរខេត្តនានា។ លោកបានជួបជាមួយអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេស ព្រមទាំងអ្នកតំណាងនានា នៃកម្មវិធីតាំងលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិ (UN-Habitat) និងសមាជិកនានានៃក្រុមអង្គការសហប្រជាជាតិនៅកម្ពុជា រួមទាំងអង្គការមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) និងអង្គការយូនេស្កូ (UNESCO)។ អ្នករាយការណ៍ពិសេសបានជួបជាមួយសមាជិកនៃសហគមន៍ប្រទេសផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល (NGOs) និងសហគមន៍មូលដ្ឋាន និងអ្នកតំណាងរបស់ពួកគេ ក៏ដូចជាមេដឹកនាំនៃជនជាតិដើមភាគតិច។

៣.  ក្រៅពីទស្សនកិច្ចនៅទីក្រុងភ្នំពេញ អ្នករាយការណ៍ពិសេសបានធ្វើទស្សនកិច្ចទៅខេត្តនានាដូចជាខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ស្ពឺ។ នៅទីក្រុងភ្នំពេញ លោកបានទៅទស្សនកិច្ច កោះពេជ្រ ទីតាំងដែលគេស្គាល់ថាជា តេ ៨៥ និង តេ ៨៦ ទីតាំងជុំវិញទន្លេបាសាក់ មន្ទីរពេទ្យមុន្នីវង្ស សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ វត្តមយូរវង្ស។ នៅខេត្តបន្ទាយមានជ័យ អ្នករាយការណ៍ពិសេស តាមដានករណីនៃការបណ្តេញចេញដោយបង្ខំ ក្នុងខែមីនា ឆ្នាំ២០០៥ នៅភូមិក្បាលស្ពាន (ឃុំប៉ោយប៉ែត) និងបានទៅសួរសុខទុក្ខសហគមន៍គីឡូលេខ៤ និងគ្រួសារប្រជាពលរដ្ឋដែលបានតាំងទីលំនៅលើដីសមាគមកសិកម្មជាតិ។ ក្នុងខេត្តសៀមរាប អ្នកតំណាងពិសេសបានតាមដានអំពីសភាពការណ៍លំនៅដ្ឋាន នៃប្រជាពលរដ្ឋជាច្រើនគ្រួសារដែលបានតាំងទីលំនៅតាមបណ្តោយស្ទឹងសៀមរាប ករណីរឿង ការដោះដូរដីធ្លី ឬ " ការលក់ដូរដី "

និងសភាពការណ៍របស់ជនជាតិដើមភាគតិចតួយ ។ នៅក្នុងខេត្តកំពង់ស្ពឺ លោកបានទៅទស្សនាភូមិមួយនៅជនបទ ក្នុងឃុំបាត់ដឹង ។ លោកក៏បានសង្កេតមើលស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ នៃភូមិមួយចំនួននៅលើទឹក និងសហគមន៍ដទៃទៀត ដែលតាំងនៅតាមបណ្តោយទន្លេផ្សេងៗក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាប និងស្តាប់ការឆ្លើយបំភ្លឺដោយអ្នកភូមិពោធិព្រៃ ។

៤. កម្មវិធីទាំងមូលសំរាប់បេសកកម្មរបស់អ្នកតំណាងពិសេស ត្រូវបានសម្របសម្រួលដោយបុគ្គលិកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (OHCHR/Cambodia) ដោយមានការជួយឧបត្ថម្ភគាំទ្រពីអង្គការ UN-Habitat ។ ការប្រជុំជាច្រើនត្រូវបានរៀបចំឡើងដោយមានការជួយឧបត្ថម្ភពីអង្គការនានាក្នុងមូលដ្ឋាន ជាពិសេស ពីសមាជិកទាំងឡាយនៃក្រុមការងារពិសេសផ្នែកសិទ្ធិខាងលំនៅដ្ឋាន ដែលជាបណ្តាញអង្គការផ្សេងៗខាងសិទ្ធិមនុស្ស និងសិទ្ធិខាងលំនៅដ្ឋាន ដែលបានបង្កើតឡើងបន្ទាប់ពីមានការបណ្តេញចេញដោយបង្ខំ និងដោយហឹង្សា នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០០៤ ។ គោលបំណងនៃក្រុមការងារនេះ គឺដើម្បីការពារមិនឱ្យមានការរំលោភសិទ្ធិខាងលំនៅដ្ឋានជាពិសេសការបណ្តេញចេញដោយបង្ខំនៅទីក្រុងភ្នំពេញ ដោយការប្រើប្រាស់មធ្យោបាយខាងសិទ្ធិមនុស្ស ។ អ្នករាយការណ៍ពិសេសសូមថ្លែងអំណរគុណដល់អ្នកទាំងនោះ ចំពោះការជួយឧបត្ថម្ភ និងការលះបង់គ្រប់បែបយ៉ាងរបស់គេ ។

៥. បេសកកម្មរបស់អ្នករាយការណ៍ពិសេស បានទទួលដោយរបាយការណ៍ និងអនុសាសន៍នានា នៃតំណាងពិសេសផ្សេងៗ នៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស និងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ត្រូវអានរបាយការណ៍នេះជាមួយនឹងរបាយការណ៍ទាំងឡាយរបស់លោកតំណាងពិសេសនានា[១] ។

៦. គោលបំណងនៃបេសកកម្មរបស់អ្នករាយការណ៍ពិសេស គឺដើម្បីពិនិត្យ និងរាយការណ៍អំពីស្ថានការណ៍នៃការទទួលបានសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានជីវភាពរស់នៅសមរម្យ រួមទាំងសេវាពាក់ព័ន្ធផ្សេងៗទៀត ដូចជា ទឹក និងអនាម័យ គោលនយោបាយសាធារណៈស្តីពីការតាំងទីលំនៅនៃមនុស្សក៏ដូចជាទៅលើទិដ្ឋភាពខាងយេនឌ័រនៃសិទ្ធិខាងលំនៅដ្ឋានសមរម្យ និងច្បាប់ពាក់ព័ន្ធ ដើម្បីការពារសិទ្ធិ

មនុស្សដែលទាក់ទងនឹងអាណត្តិរបស់លោក (ដែលមានគោលដៅជំរុញឱ្យមានការដាក់បញ្ចូលវិស័យសិទ្ធិមនុស្សនៅគ្រប់ស្រទាប់ជាន់ថ្នាក់ទាំងអស់នៃអភិបាលកិច្ច ការធ្វើ និងការអនុវត្តន៍គោលនយោបាយ)។

៧. ផ្អែកលើបទបញ្ញត្តិនៃលិខិតុបករណ៍គតិយុត្តិនានា អ្នករាយការណ៍ពិសេសបានអនុម័តនិយមន័យនៃការងារមួយអំពីសិទ្ធិមានលំនៅដ្ឋានសមរម្យថាជា "សិទ្ធិស្ត្រី បុរស យុវជន កុមារា កុមារី គ្រប់រូបក្នុងការទទួលបាន និងមានផ្ទះសម្បែងមួយគត់មត់ និងសហគមន៍ដែលពួកគេរស់នៅមានសុខសន្តិភាព និងសេចក្តីថ្លៃថ្នូរ" (E/CN.4/2001/51 កថាខ័ណ្ឌទី៨ )។ ផ្អែកលើសញ្ញាណដែលសិទ្ធិមនុស្សទាំងអស់ជាប់ទាក់ទងគ្នាទៅវិញទៅមក និងអវិភាគ អ្នករាយការណ៍ពិសេសបានអនុម័តគោលដៅទាំងមូលមួយសំរាប់អាណត្តិរបស់លោក ហើយបានស្វែងរកការផ្សារភ្ជាប់ជាមួយសិទ្ធិដទៃទៀត ដូចជាសិទ្ធិមានអាហារ ទឹក សុខភាព សិទ្ធិប្រើប្រាស់គ្រឿងសំភារៈអនាម័យ ការងារ និងទ្រព្យសម្បត្តិ សិទ្ធិសន្តិសុខនៃបុគ្គល និងសន្តិសុខនៃផ្ទះសម្បែង និងការការពារប្រឆាំងនឹងប្រព្រឹត្តកម្មអមនុស្សធម៌ និងបន្ថោកបន្ទាប នៅក្នុងសកម្មភាពទាំងអស់របស់លោក ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើជនជាតិភាគតិច និងក្រុមប្រជាពលរដ្ឋទាំងឡាយដែលងាយរងគ្រោះ ឬដែលគេមិនសូវគិតគូរអើពើ។ អ្នករាយការណ៍ពិសេសក៏បានផ្តោតការយកចិត្តទុកដាក់ជាពិសេសលើស្ត្រីភេទស្របតាមអាណត្តិរបស់លោក ក្រោមសេចក្តីសំរេចចិត្តរបស់គណៈកម្មការលេខ២០០២/៤៩, ២០០៣/២២ និង ២០០៥/២៥ ស្តីពីកម្មសិទ្ធិស្មើគ្នារបស់ស្ត្រី ការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លី និងសិទ្ធិស្មើគ្នាក្នុងការធ្វើជាម្ចាស់លើទ្រព្យសម្បត្តិ និង សិទ្ធិមានលំនៅដ្ឋានសមរម្យ។

៨. ដោយទទួលស្គាល់អំពីផលប៉ះពាល់ធ្ងន់ធ្ងរ នៃសង្គ្រាមស៊ីវិលដែលអូសបន្លាយពេលដ៏យូរអង្វែងមក និងអស្ថិរភាពនយោបាយនៅក្នុងប្រទេសកម្ពុជា និងប្រជាពលរដ្ឋរបស់ខ្លួន អ្នករាយការណ៍ពិសេសជឿជាក់ថារដ្ឋាភិបាលត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីដោះស្រាយឧបសគ្គធំៗទាក់ទងនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា រួមទាំងសិទ្ធិមានលំនៅដ្ឋានសមរម្យ។ សិទ្ធិមានលំនៅដ្ឋានសមរម្យ បើតាមសេចក្តីផ្តល់មតិទូទៅលេខ ៤ នៃគណៈកម្មាធិការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គួររាប់បញ្ចូលទាំង (ក) សន្តិសុខនៃការកាន់កាប់ស្របច្បាប់ (ខ) ការមានសេវា សំភារៈ គ្រឿងផាសុបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធ (គ) ភាពគ្រប់គ្រាន់ (ឃ) ភាពសមរម្យសំរាប់ការរស់នៅ (ង) ភាពដែលអាចប្រើប្រាស់បាន (ច) ទីតាំង និង (ឆ) ភាពគ្រប់គ្រាន់ខាង វប្បធម៌ (E/1992/23) ។

៩. ច្បាប់និងការអនុវត្តន៍ជាក់ស្តែងពាក់ព័ន្ធនឹងកម្មសិទ្ធិលើដីធ្លីមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើកត្តាមួយចំនួន ដែលបានរៀបរាប់ខាងលើស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ។ នៅពេលដែលមិនទាន់មានច្បាប់ ឬបញ្ញត្តិច្បាប់មិនបានចែងច្បាស់លាស់អំពីភាពខុសគ្នារវាងដីរដ្ឋ និងដីឯកជន កិច្ចការជំនួញទាក់ទិននឹងដីសាធារណៈសម្បទានដី និងដីសមូហភាពរបស់ជនជាតិដើមភាគតិច ឧទាហរណ៍ ដោយសារតែមានភាពមិនច្បាស់លាស់ទើបធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិមានលំនៅដ្ឋានសមរម្យ។ ភាពមិនច្បាស់លាស់នៃច្បាប់បន្ថែមលើបរិបទនៃអំពើពុករលួយ ប្រព័ន្ធតុលាការទន់ខ្សោយទៅតាមនោះ ការគូសផែនទីដីរដ្ឋមិនបានគ្រប់សព្វ និងដោយសារការខ្វះការយល់ដឹងអំពីច្បាប់ ទើបប្រជាពលរដ្ឋជាច្រើនដែលអាចស្នើសុំលិខិតកាន់កាប់ដីធ្លីផ្លូវការមិនដឹងពីនីតិវិធីដែលត្រូវអនុវត្ត ឬមិនដឹងពីសារៈសំខាន់នៃលិខិតនោះ។

១០. ប្រព័ន្ធច្បាប់មួយដែលមិនរឹងមាំនៅក្នុងបរិបទនយោបាយសង្គមនេះ នាំឱ្យមានភាពមិនប្រក្រតីជាច្រើន។ អ្នករាយការណ៍ពិសេសមានការព្រួយបារម្ភថា ភាពមិនប្រក្រតីទាំងនេះ អាចមានផលប៉ះពាល់ជាអវិជ្ជមានទៅលើសិទ្ធិក្នុងការរស់នៅ សិទ្ធិប្រើប្រាស់ និងភាពសមរម្យខាងវប្បធម៌ នៃសិទ្ធិខាងលំនៅដ្ឋាន និងអាចបណ្តាលឱ្យមានការបណ្តេញចេញ ឬការផ្លាស់ទីលំនៅដោយបង្ខំ។ អនុលោមតាមព័ត៌មានដែលអ្នករាយការណ៍ពិសេសប្រមូលបាន នៅក្នុងដំណើរបេសកកម្មរបស់លោក ប្រព័ន្ធគ្រប់គ្រងដីធ្លី និងលំនៅដ្ឋានដែលមានស្រាប់រហូតមកទល់ពេលនេះ មិនអាចដោះស្រាយបញ្ហានេះបានសមស្របទេ។

## I- ក្របខ័ណ្ឌនៃនិយាមជាតិ និងអន្តរជាតិសំរាប់សិទ្ធិមានលំនៅដ្ឋានសមរម្យនៅក្នុងប្រទេសកម្ពុជា ជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ

### ក- កាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

១១. រដ្ឋាភិបាលកម្ពុជាបានអនុម័តយល់ព្រមលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ១៩៩២ រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) ដែលបានធានាការពារយ៉ាងច្បាស់នូវសិទ្ធិមានលំនៅដ្ឋានសមរម្យ ជាសមាសធាតុមួយនៃសិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ។ រដ្ឋាភិបាលបានដាក់

ជូនរបាយការណ៍លើកដំបូងក្រោមសន្ធិសញ្ញាទាំងនេះ លើកលែងតែរបាយការណ៍ដំបូងក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលគេរំពឹងថានឹងបានដាក់ជូននៅក្នុងឆ្នាំ២០០៦។ ចាប់តាំងពីឆ្នាំ២០០១ រហូតមក ការិយាល័យប្រចាំកម្ពុជា (OHCHR/Cambodia) បានជួយគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាលក្នុងការរៀបចំធ្វើរបាយការណ៍ដំបូង។ ការិយាល័យក៏បានជួយគណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាល ផ្នែកឃ្លាំមើលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្នុងការរៀបចំរបាយការណ៍ស្របគ្នាមួយដែលបានចេញផ្សាយកាលពីខែកញ្ញាឆ្នាំ២០០២។ របាយការណ៍បានបញ្ចូលនូវអនុសាសន៍សំខាន់ៗជាច្រើនទាក់ទងនឹងសិទ្ធិខាងលំនៅដ្ឋាន ដូចជាការប្រើភាពគ្មានដីធ្លី ជាសូចនាករសំរាប់ការកាត់បន្ថយភាពក្រីក្រ និងការគាំទ្រដល់ឱកាសបង្កើនចំណូលផ្សេងៗសំរាប់កសិករដែលបាត់បង់ដីធ្លី[២] ។

## ខ- សិទ្ធិមានលំនៅដ្ឋានសមរម្យ និងអង្គការសហប្រជាជាតិនៅកម្ពុជា

១២. មជ្ឈមណ្ឌលសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (ដែលក្រោយមកបានប្តូរឈ្មោះមកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស) នៅកម្ពុជា និងអាណត្តិរបស់តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ត្រូវបានបង្កើតឡើងដោយគណៈកម្មការសិទ្ធិមនុស្សក្នុងឆ្នាំ១៩៩៣ ហើយបានដំណើរការនៅក្នុងឆ្នាំដដែល បន្ទាប់ពីការចាកចេញរបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) ។

១៣. ចាប់តាំងពីការចាប់ផ្តើមបំពេញអាណត្តិរបស់ខ្លួន ទាំងការិយាល័យប្រចាំកម្ពុជា (OHCHR/Cambodia) ទាំងតំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានទទួលព័ត៌មាន និងរបាយការណ៍អំពីករណីជាច្រើនពាក់ព័ន្ធនឹងស្ថានភាពលំនៅដ្ឋានមិនសមរម្យ ជាពិសេសស្ថិតក្នុងអាណត្តិការពាររបស់ខ្លួន។ តំណាងពិសេសមុនៗបានលើកឡើងជាច្រើនលើកច្រើនសាររួចមកហើយនូវអនុសាសន៍ស្នើសុំឱ្យចាត់វិធានការជាបន្ទាន់ ដើម្បីដោះស្រាយការរំលោភសិទ្ធិខាងលំនៅដ្ឋានទាក់ទងនឹងស្ថានភាពកុមារ និងស្ត្រីដែលរស់នៅតំបន់ក្រីក្រ ការប្រើប្រាស់ទឹកទទួលទាន សុខភាព និងអនាម័យ ការបណ្តេញចេញដោយបង្ខំ ជាពិសេស ក្រុមជនជាតិភាគតិចនានា និងនៅតាមតំបន់ព្រំដែនក្នុងស្រុកប៉ោយប៉ែត ការផ្លាស់ទីលំនៅ ការតាំងទីលំនៅថ្មី និងការផ្តល់សំណងជួសជុលការខូចខាត (សូមមើលជាពិសេស របាយការណ៍លេខ E/CN.4/2001

/103 កថាខ័ណ្ឌ ទី៦៧, របាយការណ៍លេខ A/56/209 កថាខ័ណ្ឌទី២៣-៣២ និងរបាយការណ៍លេខ E/CN.4/ 2002/118 កថាខ័ណ្ឌទី៨១។

១៤. នៅក្នុងអំឡុងឆ្នាំ២០០១ និងឆ្នាំ២០០២ គណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ចអង្គការសហប្រជាជាតិសំរាប់តំបន់អាស៊ីប៉ាស៊ីហ្វិក(ESCAP) បានផ្តល់ការជួយឧបត្ថម្ភដល់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ក្នុងវិស័យនៃការសាងសង់លំនៅដ្ឋានដែលមានតំលៃទាប ដែលក្រោយមកបានប្រែក្លាយទៅជាឯកសារយុទ្ធសាស្ត្រជាតិខាងលំនៅដ្ឋាន។ បន្ទាប់មក គំនិតផ្តួចផ្តើមនេះបានក្លាយទៅជាកិច្ចព្រមព្រៀងមួយរវាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) អង្គការ(UN-Habitat) អង្គការ(ESCAP) និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីបង្កើតគោលនយោបាយជាតិខាងលំនៅដ្ឋាន ដែលនៅពេលថ្មីៗនេះត្រូវបានអនុម័តដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ សំណុំឯកសារដាក់ចេញនូវគោលនយោបាយមួយចំនួនក្នុងវិស័យនៃការផ្តល់ថវិកាសំរាប់សងលំនៅដ្ឋាន ការរៀបចំស្ថាប័ន បទដ្ឋាននានាសំរាប់អភិវឌ្ឍដីធ្លី និងការសាងសង់អគារ និងការបង្កើតកម្មវិធីខាងលំនៅដ្ឋាន ដែលជាសមាសធាតុនៃផែនការមេ។

១៥. អ្នករាយការណ៍ពិសេសទទួលស្គាល់ និងគាំទ្រដល់ការងាររបស់ការិយាល័យប្រចាំកម្ពុជា (OHCHR /Cambodia) និងលោកតំណាងពិសេស ហើយសូមបញ្ជាក់ថា បេសកកម្មថ្នាក់ប្រទេសរបស់លោក នេះគឺគ្រាន់តែជាការបំពេញបន្ថែមទៅលើសកម្មភាពស្វែងរកការពិត ការតាមឃ្លាំមើល និងការរាយការណ៍ រយៈពេលជាង១០ឆ្នាំរបស់អង្គការសហប្រជាជាតិនៅកម្ពុជាតែប៉ុណ្ណោះ។

## គ- រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ និងច្បាប់ភូមិបាល ឆ្នាំ២០០១

១៦. ក្រៅពីការទទួលស្គាល់ និងការគោរព " សិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញានានាទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិ ស្ត្រី និងសិទ្ធិកុមារ " រដ្ឋធម្មនុញ្ញកម្ពុជាទទួលស្គាល់សិទ្ធិកម្មសិទ្ធិលើដីធ្លីឯកជនផងដែរ។

១៧. អនុលោមតាមរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ និងច្បាប់ភូមិបាល ឆ្នាំ២០០១ គឺគ្មានជនណាម្នាក់ត្រូវបានគេដកហូតសិទ្ធិលើកម្មសិទ្ធិរបស់ខ្លួនឡើយ លុះត្រាតែជាការចាំបាច់សំរាប់ផលប្រយោជន៍សាធារណៈ។ នៅពេលណាដែលកើតមានការដកហូតបែបនេះ គេត្រូវតែអនុវត្តស្របទៅតាមនីតិវិធីដែលច្បាប់បានចែង ហើយអាចធ្វើបានបន្ទាប់ពីមានការទូទាត់សងប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌តែប៉ុណ្ណោះ។ បញ្ញត្តិទាំងនេះមានសារៈសំខាន់ជាពិសេសក្នុងការការពារសិទ្ធិខាងលំនៅដ្ឋានពីការបណ្តេញចេញដោយបង្ខំ។

១៨. ច្បាប់ភូមិបាលឆ្នាំ២០០១ កំណត់ពីភាពខុសគ្នារវាងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ច្បាប់នេះក៏ចែងផងដែរអំពីរបបគតិយុត្តផ្សេងៗគ្នានៃកម្មសិទ្ធិឯកជន (កម្មសិទ្ធិឯកត្តជន កម្មសិទ្ធសមូហភាព កម្មសិទ្ធិអវិភាគ និងសហកម្មសិទ្ធិ )។ របបទាំងនេះមានលក្ខណៈខុសប្លែកគ្នាទៅតាម " សេចក្តីត្រូវការនៃសង្គមកម្ពុជា " ដូចជាអចលនវត្ថុនៅទីក្រុង ដីកសិកម្ម ព្រៃ និងដីសំរាប់សាងសង់តំបន់អភិវឌ្ឍន៍ឧស្សាហកម្មក្នុងចំណោមដីផ្សេងៗទៀត។ របបគតិយុត្តនីមួយៗ ត្រូវបានកំណត់ដោយបទបញ្ញត្តិនៃច្បាប់ដោយឡែក។

១៩. របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់ដោយច្បាប់ភូមិបាលឆ្នាំ២០០១ឡើយ។ ច្បាប់នេះចែងថាកម្មសិទ្ធិសាធារណៈ គឺជាទ្រព្យដែលមិនមែនជាកម្មវត្ថុនៃការយកធ្វើជារបស់ឯកជន ឬសមូហភាព ឬមិនមែនជាទ្រព្យដែលកំពុងកាន់កាប់ជារបស់ឯកជន ឬជាសមូហភាព។

២០. ចំពោះដីឯកជន ច្បាប់នេះចែងអំពីយន្តការមួយ ដើម្បីការពារសិទ្ធិខាងដីធ្លី និងសិទ្ធិខាងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋកម្ពុជាដែលតាមរយៈនេះ សិទ្ធិភោគៈលើលំនៅដ្ឋាន និងដីធ្លីនេះ នឹងអាចទៅដល់លទ្ធកម្មនៃកម្មសិទ្ធ។ បុគ្គលដែលបានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ (ប្រាំ) ឆ្នាំនៅលើអចលនវត្ថុអាចបង្កើតនូវសិទ្ធិភណ្ឌិកលើអចលនវត្ថុនោះ ហើយអាចស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរបាន។

២១. បញ្ញត្តិសំខាន់មួយទៀតនៃច្បាប់នេះ ទាក់ទងនឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី គឺការទទួលស្គាល់ដីប្រពៃណីដែលកាន់កាប់ដោយជនជាតិដើមភាគតិច (សំរាប់គោលបំណងធ្វើជាលំនៅដ្ឋាន និងធ្វើកសិកម្ម) ជាកម្មសិទ្ធិសមូហភាពនៃសហគមន៍ទាំងនោះ។ ជាគោលការណ៍ បញ្ញត្តិនេះគួរការពារជនជាតិដើមភាគតិចពីការបណ្តេញចេញ។

២២. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទទួលខុសត្រូវគ្រប់គ្រងអចលនទ្រព្យទាំងអស់របស់រដ្ឋ និងចេញប័ណ្ណកម្មសិទ្ធិលើដីធ្លីទូទាំងប្រទេសកម្ពុជា។ ច្បាប់នេះបង្កើតផងដែរនូវរដ្ឋបាលសុរិយោដី ក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចកំណត់អត្តសញ្ញាណនៃទ្រព្យ កសាងប្លង់សុរិយោដី ចេញប័ណ្ណកម្មសិទ្ធិ ចុះបញ្ជីដីធ្លី និងជូនដំណឹងដល់ប្រជាពលរដ្ឋអំពីស្ថានភាពក្បាលដីនីមួយៗ។

២៣. មាត្រា១៥ ធ្វើការបរិយាយអំពីប្រភេទទ្រព្យដែលរាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋ។ បញ្ជីលំអិតនេះ រាប់ចូលនូវទ្រព្យទាំងឡាយ ដែលត្រូវបានដាក់ឱ្យដំណើរការសំរាប់សេវាសាធារណៈ ដូចជាសាលារៀន ឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានការភាន់ច្រឡំយ៉ាងច្រើន ទាក់ទងនឹងការបែងចែកឱ្យដាច់ស្រឡះពីគ្នារវាងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ សូម្បីតែមន្ត្រីមួយចំនួនក៏មានការយល់ច្រឡំដែរ។ ការកំណត់ភាពខុសប្លែកគ្នានេះមានសារៈសំខាន់ណាស់ អាស្រ័យដោយមានបញ្ញត្តិមួយចំនួននៃច្បាប់ភូមិបាល ឆ្នាំ២០០១ ចែងពីការប្រើប្រាស់ដីធ្លី ហើយសំខាន់ជាងនេះទៀតនោះ គឺការផ្ទេរកម្មសិទ្ធិនៃសម្បត្តិរដ្ឋទាំងពីរប្រភេទនេះ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ ទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ផ្ទុយទៅវិញទ្រព្យសម្បត្តិឯកជនរបស់រដ្ឋអាចជាកម្មវត្ថុនៃការលក់ ការដូរ ឬការកាន់កាប់ជាឯកជនបាន។ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីធ្លីដែលត្រូវបានអនុម័ត កាលពីខែកញ្ញា ឆ្នាំ២០០៥ ចែងយ៉ាងច្បាស់ថែមទៀត ដោយតម្រូវឱ្យកំណត់អត្តសញ្ញាណនៃសម្បត្តិរដ្ឋ ការកសាងប្លង់សុរិយោដី និងការធ្វើចំណាត់ថ្នាក់ដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ។ កិច្ចដំណើរការនេះ ត្រូវតែអនុវត្តដោយប្រុងប្រយ័ត្ន ជៀសវាងការភាន់ច្រឡំ និងការផ្ទេរកម្មសិទ្ធិដីធ្លី។

២៤. កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ នាយករដ្ឋមន្ត្រីបានចេញបទបញ្ជាលេខ ០២ បប ដែលមានចំណងជើងថា " បទបញ្ជាស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ " ដែលទំនងជាការហាមឃាត់ការដោះដូរសម្បត្តិសាធារណៈរបស់រដ្ឋ ការអនុញ្ញាតឱ្យមានការដោះដូរដីបាន លុះត្រាតែច្បាប់បានប្តូរសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅជាសម្បត្តិឯកជនរបស់រដ្ឋ ដោយត្រូវរងចាំការអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ។ សារាចរលេខ៥ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីបទបញ្ជាលេខ ០២ បប បានធ្វើការណែនាំដល់ក្រសួង

និងស្ថាប័នពាក់ព័ន្ធទាំងអស់ឱ្យអនុវត្តតាមបទបញ្ជានេះ  រង់ចាំការអនុម័តអនុក្រឹត្យស្តីពីសម្បទានដីគោលដៅសេដ្ឋកិច្ច ដែលត្រូវបានអនុម័តកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥។ អនុក្រឹត្យទាំងពីរនេះ ចែងថា នៅមុនពេលផ្តល់សម្បទានដីតទៅទៀត  ដីសាធារណៈរបស់រដ្ឋទាំងអស់ត្រូវតែធ្វើចំណាត់ថ្នាក់  ចុះបញ្ជី  និងកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់។ បច្ចុប្បន្ន អនុក្រឹត្យទាំងពីរនេះ ទាមទារឱ្យមានការរៀបចំ និងការអនុម័តបទបញ្ជាអនុវត្តបន្ថែមទៀត។ គេចាំបាច់ត្រូវធ្វើការពិនិត្យឃ្លាំមើលឱ្យបានជិតដល់ ដោយផ្អែកលើបទពិសោធន៍កន្លងមក។

២៥. " ការដោះដូរដីធ្លី ឬការលក់ដូរដី " ដែលកើតមាននៅពេលថ្មីៗនេះ រួមមានការដោះដូរដីមួយចំនួន ដែលអ្នករាយការណ៍ពិសេសបានឃើញ   ធ្វើឱ្យលោកនឹកឃើញដល់រយៈពេលប៉ុន្មានឆ្នាំដែលសេដ្ឋកិច្ចរីកចំរើននៅដើមទសវត្សឆ្នាំ១៩៩០  នៅពេលដែលអគារសាធារណៈចាស់ៗជាច្រើន  នៅកណ្តាលទីក្រុងត្រូវបានគេវាយគំទេចចោល ដើម្បីបានប្រាក់ចំណេញឆាប់រហ័ស។ បច្ចុប្បន្ននេះ យ៉ាងហោចណាស់ ការលក់ដូរដីធ្លី គឺជាផ្នែកមួយនៃគោលការណ៍ដោះដូរដីធ្លី   ទោះបីជាទំនងជាផលប្រយោជន៍សេដ្ឋកិច្ចឯកជនបានមកពីការដោះដូរដីដែលផ្ទុយទៅផលប្រយោជន៍សាធារណៈក៏ដោយ។  ដូចបានកត់សំគាល់រួចមកហើយ  សូម្បីតែនៅមុនការអនុម័តអនុក្រឹត្យពីរដែលបានរៀបរាប់ខាងលើ  អ្វីដែលគេហៅថាការដោះដូរដីជាច្រើន ធ្វើឡើងដោយមិនអើពើចំពោះបញ្ញត្តិច្បាប់ដែលមានស្រាប់។ គេត្រូវខិតខំប្រឹងប្រែង ដើម្បីធានាថានីតិវិធីថ្មី និងដែលស្មុគស្មាញខ្លាំង ពាក់ព័ន្ធទៅនឹងសម្បទានដី ត្រូវតែគោរពតាមនៅក្នុងការអនុវត្តន៍ជាក់ស្តែង។

## II- ស្ថានភាពខាងលំនៅដ្ឋាន : ទិដ្ឋភាពរួម

២៦- ជម្លោះ និងសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ នាំឱ្យមានការរំលោភយកដីដ៏ធ្ងន់ធ្ងរ ដែលបានបណ្តាលអោយមានជម្លោះដីធ្លីកើតមានកាន់តែខ្លាំងឡើងៗ   ហើយប្រែប្រួលលំនាំនៃកម្មសិទ្ធិធ្វើអោយបាត់បង់អត្ថប្រយោជន៍ប្រជាជនក្រីក្រទាំងនៅជនបទនិងនៅទីក្រុង។  ប្រព័ន្ធគ្រប់គ្រងដីធ្លីមិនអាចរកដំណោះស្រាយបាន  ជារួមគឺដោយសារការគ្មានបញ្ជីដីធ្លីព្រោះបញ្ជីនេះត្រូវបានបំផ្លាញនៅក្នុងរបបប៉ុលពត ពុំទាន់មានការអភិវឌ្ឍន៍ ហើយនិងគ្មានតម្លាភាពក្នុងប្រព័ន្ធចុះបញ្ជីដីធ្លី  ពុំមានការកសាងផ្លូវសុរិយោដី  ច្បាប់ភូមិបាល  និងនីតិវិធីមិន

គ្រប់គ្រាន់ ការកំណត់ព្រំប្រទល់ដីរដ្ឋមិនច្បាស់លាស់ ហើយនិងភាពទន់ខ្សោយនៃប្រព័ន្ធយុត្តិធម៌ ទាំងនេះបាន ធ្វើឱ្យបញ្ហានេះនៅតែមានជាបន្ត។

២៧- ដូចបានរៀបរាប់ខាងលើ ជាគោលការណ៍ ច្បាប់ភូមិបាល២០០១ បានផ្តល់នូវសុវត្ថិភាពសិទ្ធិដីធ្លីនិងសិទ្ធិលំនៅដ្ឋានដល់ប្រជាពលរដ្ឋកម្ពុជា។ បើតាមការអនុវត្តជាក់ស្តែង វានៅតែមានការពិបាកសំរាប់ប្រជាពលរដ្ឋក្រីក្រក្នុងការទទួលបាននូវសិទ្ធិទាំងនេះដោយសារហេតុផលជាច្រើន។ ហេតុផលទាំងនេះរួមមាន ដោយសារការគ្មានអនុក្រឹត្យសំខាន់ៗមួយចំនួន ដើម្បីអនុវត្តច្បាប់ភូមិបាល ដូចដែលបានកត់សំគាល់ ក្នុងបរិបទលំនៅដ្ឋានក្រោមការគ្រប់គ្រងដីរដ្ឋ កង្វះពតិមានស្តីពីខ្លឹមសារនៃច្បាប់ ហើយនិងការដែលអាជ្ញាធរសាធារណៈ និងតុលាការអនុវត្តច្បាប់ពុំបានពេលលេញ។ ទាំងនេះគឺកើតមានជាក់ស្តែងនៅតំបន់ជនបទ ប៉ុន្តែវាក៏មានករណីទាំងនេះផងដែរនៅទីក្រុង ដោយសារការកើនឡើងនៃចំនួនប្រជាពលរដ្ឋ និងការរីកចំរើនយ៉ាងឆាប់រហ័សនៃទីក្រុង។

២៨- នៅចុងឆ្នាំ២០០៤ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានអនុម័តយល់ព្រមលើសេចក្តីព្រាងគោលនយោបាយជាតិស្តីពីលំនៅដ្ឋាន។ គោលនយោបាយជាតិស្តីពីលំនៅដ្ឋានរួមមានការផ្តួចផ្តើមលើបញ្ហាការកាន់កាប់ដីធ្លី ដោយបញ្ចូលការផ្អាកជាបណ្តោះអាសន្នរយៈពេលវែង និងខ្លីនូវការតាំងទីលំនៅថ្មី និងការបណ្តេញចេញ ការអភិវឌ្ឍន៍ទីតាំងនៅនឹងកន្លែងលើដីរដ្ឋ វិធានការផ្លូវច្បាប់ដើម្បីធានាការទទួលបាននូវសេវាកម្មចាំបាច់មួយចំនួន ហើយនិងការអនុម័តក្រមស្តីពីការសាងសង់អគារដែលមានសណ្ឋានតែមួយ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានធ្វើកម្មវិធីសាកល្បងនៅខេត្តបាត់ដំបង ដើម្បីបញ្ជាក់ថាតើគោលនយោបាយដែលបានដាក់ស្នើនេះអាចធ្វើបានដែរឬទេ។ គេរំពឹងថាសេចក្តីព្រាងគោលនយោបាយជាតិស្តីពីលំនៅដ្ឋាននេះនឹងត្រូវបានអនុម័តជាអនុក្រឹត្យក្នុងរយៈពេលពីរឆ្នាំខាងមុខនេះ។ ទោះជាយ៉ាងណាក្តី សេចក្តីព្រាងនេះមិនបានយកចិត្តទុកដាក់ដល់កាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ឡើយ ជាពិសេសពាក់ព័ន្ធលើការការពារ និងការលើកស្ទួយសិទ្ធិមានកំរិតជីវភាពសមរម្យ។

២៩- ពីព្រោះការខ្វះចន្លោះបទបញ្ញត្តិ និងការអនុវត្តន៍ច្បាប់ដែលមានស្រាប់ពុំបានពេញលេញនោះ វានឹងបណ្តាលឱ្យកើតមានឡើងនូវការបណ្តេញចេញដោយបង្ខំ និងការតាំងទីលំនៅថ្មី និងការបាត់បង់ទីលំនៅដ្ឋាន

នៃគ្រួសារជាច្រើននាពេលអនាគតដ៏ឆាប់ខាងមុខ។ នេះវាអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បញ្ហាសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋកម្ពុជា។ របាយការណ៍ និងសាក្សីកម្មដែលអ្នករាយការណ៍ពិសេសទទួលបានបញ្ជាក់ពីការព្រួយបារម្ភទាំងនេះ។

## ក- ការដោះដូរដីធ្លី ឬ " ការលក់ដូរដី "

៣០- ទម្រង់មួយនៃទម្រង់ជាច្រើននៃការលក់ដីសាធារណៈរបស់រដ្ឋ ដែលកំពុងតែកើតមាននៅក្នុងប្រទេសកម្ពុជា គឺធ្វើឡើងតាមរយៈ ការដោះដូរដីធ្លី ឬ ការលក់ដូរដី។ ក្នុងការជួញដូរនេះ ដីសាធារណៈរបស់រដ្ឋដែលមានទីតាំងនៅកណ្តាលទីក្រុងត្រូវបានគេប្តូរជាមួយនិងដីនៅជាយក្រុង។ ដីសាធារណៈរបស់រដ្ឋដែលនៅក្នុងក្រុងគឺជាអគារដែលសំរាប់ផ្តល់សេវាសាធារណៈ ដូចជា មន្ទីរពេទ្យ សាលារៀន ពហុកីឡាដ្ឋាន និងមជ្ឈមណ្ឌលវប្បធមិនានា។ ក្នុងអំឡុងឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩០ រដ្ឋាភិបាលបានសំរួលឱ្យគ្រួសារជាច្រើនតាំងទីលំនៅ នៅក្នុង និងនៅជុំវិញអគារទាំងនេះ។ ក្នុងករណីជាច្រើន ការដោះដូរដីធ្លី ឬ ការលក់ដូរដី បានបណ្តាលឱ្យគ្រួសារជាច្រើនផ្លាស់ប្តូរទីលំនៅ ដែលជានិច្ចជាកាលទៅកាន់កន្លែងថ្មីដែលខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ ហើយគ្មានទឹក និងប្រព័ន្ធអនាម័យ។ អំឡុងពេលបំពេញបេសសកម្ម អ្នករាយការណ៍ពិសេសបានទទួលរបាយការណ៍ជាច្រើនស្តីពីការដោះដូរដីធ្លី ឬ ការលក់ដូរដីនេះ ជាពិសេសនៅខេត្តសៀមរាប និងនៅទីក្រុងភ្នំពេញ។

៣១- ក្នុងខែមករាឆ្នាំ២០០៥ គេបានដោះដូរអធិការដ្ឋាននគរបាលក្រុងភ្នំពេញ ជាមួយនិងអគារថ្មីមួយ ដែលគេសាងសង់នៅលើដីដែលមានទីតាំងនៅខ័ណ្ឌឬស្សីកែវ ចម្ងាយ៩គីឡូម៉ែត្រពីទីក្រុងភ្នំពេញ។ ក្នុងខែជាមួយគ្នានេះដែរ ក្រុមហ៊ុនក្តីសង្ឃឹមថ្មី (New Hope Co., Ltd.) បានយល់ព្រមចំណាយលើការសាងសង់អគារក្រសួងទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភា និងអធិការកិច្ច លើដីអតីតជាដីសាធារណៈរបស់រដ្ឋដែលមានទីតាំងនៅសង្កាត់ទន្លេបាសាក់ក្រុងភ្នំពេញ។ ក្នុងខែកុម្ភៈ ក្រសួងមហាផ្ទៃបានលក់មន្ទីរពេទ្យព្រះមុន្នីវង្សទៅឱ្យក្រុមហ៊ុនរ៉ូយាល់គ្រុប ដែលជាអ្នកគ្រប់គ្រងលើបណ្តាញទូរទស្សន៍កម្ពុជា និងក្រុមហ៊ុនទូរស័ព្ទចល័ត ម៉ូប៊ីតែល។ ក្នុងខែកុម្ភៈដដែលនេះ ក្រុមហ៊ុនអភិវឌ្ឍន៍ម៉ុងឬទ្ធីគ្រុបបានអះអាងពីការដែលខ្លួនទទួលបានការយល់ព្រមពីក្រសួងវប្បធមិ និងវិចិត្រសិល្បៈ ដើម្បីសាងសង់បរិវេណសិល្បៈថ្មីនៅក្នុងខ័ណ្ឌឬស្សីកែវ ជាមួយនិងការដោះដូរដីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (RUFA) ដែលមានទីតាំងនៅចំកណ្តាលទីក្រុងភ្នំពេញ ។

ក្នុងខែមិនា ទីស្ដីការគណៈរដ្ឋមន្ត្រីបានបញ្ជាក់ពីការលក់វិទ្យាស្ថានពហុបច្ចេកវិជ្ជាទៅឱ្យក្រុមហ៊ុនឯកជនមួយ។ យោលតាមរបាយការណ៍ពីប្រព័ន្ធព័ត៌មានបានឱ្យដឹងថា នៅក្នុងខែឧសភាឆ្នាំ២០០៥ លោកនាយករដ្ឋមន្ត្រីយល់ព្រមចរចាលក់ដូរតុលាការកំពូល សាលាឧទ្ធរណ៍ តុលាការក្រុងភ្នំពេញ ហើយនិងក្រសួងយុត្តិធម៌ទៅឱ្យក្រុមហ៊ុន ម៉ុងឬទ្ធីគ្រុប ជាមួយនិងថ្នូរនូវអគារថ្មីដែលស្ថិតនៅជាយក្រុងភ្នំពេញ។ តែទោះជាយ៉ាងណាក៏ដោយគ្មានការអះអាងច្បាស់លាស់ពីការលក់ដូរនេះនៅឡើយទេ ហើយអ្នករាយការណ៍ពិសេសសង្ឃឹមថាការលក់ដូរនេះមិនបន្តទៅទៀតឡើយ។

៣២- នៅក្នុងកិច្ចប្រជុំជាផ្លូវការ មន្ត្រីសាធារណៈជាន់ខ្ពស់មួយចំនួនបានបញ្ចេញទស្សនៈថា ការដោះដូរទ្រព្យសម្បត្តិទាំងនេះមានសារសំខាន់ណាស់ចំពោះការអភិវឌ្ឍន៍ទីក្រុង ការស្តារឡើងវិញ និងការពង្រីកអគាររដ្ឋាភិបាល ដោយហេតុថារដ្ឋាភិបាលពុំមានធនធានគ្រប់គ្រាន់ឡើយ។ តែទោះជាយ៉ាងណា អ្នករាយការណ៍ពិសេសគឺតថា ខណៈដែលផ្តួចផ្តើមរកដំណោះស្រាយចាប់យកដៃគូជាមួយផ្នែកឯកជនដោយហេតុថាខ្វះធនធានសាធារណៈនោះ គឺគេអាចធ្វើទៅបានតាមដំណោះស្រាយទាំងនេះ តែត្រូវធ្វើតាមវិធានការមួយដែលហ្មត់ចត់បំផុតនៃការចូលរួមពីសាធារណៈជន ផ្តល់ព័ត៌មានជាសាធារណៈ កិច្ចសន្យាដេញថ្លៃជាសាធារណៈ ហើយនីតិវិធីគឺធ្វើទៅតាមច្បាប់។ ការព្រួយបារម្ភខ្លាំងបំផុតលើបញ្ហាទាំងនេះគឺការខ្វះតម្លាភាព។ ការចរចាលក់ដូររវាងរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនត្រូវបានធ្វើឡើងរួចរាល់អស់រយៈពេលយ៉ាងយូរ ទើបបានគេបញ្ចេញឱ្យដឹងជាសាធារណៈ។

៣៣- ក្រុមគ្រួសារភាគច្រើនដែលរងការប៉ះពាល់ដោយការដោះដូរដីនេះ គឺគ្រួសារខ្លះបានរស់នៅលើដីរដ្ឋនេះអស់រយៈពេលជាង១០ឆ្នាំកន្លងមកហើយ ពួកគាត់បានធ្វើការសាងសង់ អភិវឌ្ឍន៍នៅនឹងកន្លែង ពង្រីកផ្ទះសម្បែងរបស់ពួកគាត់។ បើយោលទៅតាមច្បាប់ភូមិបាលឆ្នាំ២០០១ គ្រួសារទាំងនេះមានសិទ្ធិកាន់កាប់ដីទាំងនេះ។ ដូច្នេះ ការបាត់បង់ទ្រព្យសម្បត្តិរបស់គាត់យ៉ាងហោចណាស់ត្រូវទទួលបាននូវសំណងត្រឹមត្រូវនិងសមស្រប។ ជាក់ស្តែង តម្លៃនៃសំណងដែលក្រុមហ៊ុនផ្តល់អោយគឺទាបបំផុត បើប្រៀបធៀបទៅនិងតម្លៃទីផ្សារ ហើយមិនដែលបានគ្រប់គ្រាន់ឡើយ។ ឧទាហរណ៍ តម្លៃដែលផ្តល់អោយនៅមន្ទីរពេទ្យព្រះមុន្នីវង្ស និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ គឺតិចជាង២០ដុល្លាក្នុងមួយម៉ែត្រការ៉េ ដែលកន្លែងខ្លះតម្លៃទីផ្សារបើតាមការប៉ាន់ស្មានគឺមានតម្លៃរហូតដល់២០០០ដុល្លាអាមេរិក ក្នុងមួយម៉ែត្រការ៉េ។ ក្នុងករណីជាច្រើន

ដែលអ្នករាយការណ៍ពិសេសបានសិក្សាឃើញថា គេបានប្រើប្រាស់ការបំភិតបំភ័យ និងការគំរាមកំហែង ដើម្បីជំរុញឱ្យក្រុមគ្រួសារទាំងនោះទទួលយកការដោះដូរយ៉ាងមិនត្រឹមត្រូវនេះ ។

៣៤- នៅពេលគេផ្តល់ទីតាំងសំរាប់តាំងលំនៅដ្ឋានថ្មី ជាទូទៅតែងតែស្ថិតនៅឆ្ងាយពីទីក្រុង ហើយឆ្ងាយពីកន្លែងដែលរស់នៅចាស់ ។ ជាលទ្ធផលវាបានធ្វើអោយបាត់បង់ការងារ និងចំណូល ដោយសារតែខ្វះមធ្យោបាយ និងការចំណាយលើការធ្វើដំណើរ ។ លើសពីនេះទៀត នៅទីតាំងសំរាប់លំនៅដ្ឋានថ្មីពុំមានសេវាកម្មចាំបាច់នានា ហើយគេពុំបានផ្តល់ជំរកបណ្តោះអាសន្នក្នុងអំឡុងពេលសាងសង់ផ្ទះថ្មីនោះឡើយ ។ នៅក្នុងករណីដោះដូរដីជាច្រើន ជាលទ្ធផលគឺរំខានដោយសេវាកម្មទាំងនេះ ដោយហេតុថាអគារនៅកន្លែងចាស់ត្រូវបានគេបំផ្លាញចោលមុនអគារនានានៅកន្លែងថ្មីសាងសង់រួច ។

៣៥- យោលទៅតាមបទបញ្ញត្តិនៃច្បាប់ភូមិបាលឆ្នាំ២០០១ សូម្បីតែអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋដែលទើបតែបានអនុម័តថ្មីៗនេះ ក៏ចែងថាការដោះដូរដីគឺខុសច្បាប់ ។ បទបញ្ជារបស់នាយករដ្ឋមន្ត្រី លេខ០២បបស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ បានបញ្ជាក់ថា គ្មានការដោះដូរទ្រព្យសម្បត្តិរបស់រដ្ឋប្រព្រឹត្តទៅមុនការអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឡើយ ។ ភាគច្រើនបានបកស្រាយថាបទបញ្ជាគ្មានប្រតិសកម្មទេ គឺមានប្រសិទ្ធិភាពតែលើការដោះដូរណាដែលធ្វើឡើងក្រោយតែពីថ្ងៃនៃការចេញបទបញ្ជានេះតែប៉ុណ្ណោះ ។ ចាប់តាំងតែពីបានចេញបទបញ្ជានេះមក ពុំមានរបាយការណ៍ស្តីពីការដោះដូរដីកើតមានឡើយ តែគេត្រូវយកមកគិតគូពីសេចក្តីរាយការណ៍មួយចំនួនលើការដោះដូរដីដែលកើតមានមុនបទបញ្ជានេះបានចេញ ។ ដោយហេតុថាបទបញ្ជារបស់នាយករដ្ឋមន្ត្រីបានជួយពង្រឹងសារជាថ្មីដល់តម្រូវការច្បាប់របស់កម្ពុជា អ្នករាយការណ៍ពិសេសជឿជាក់ថា បទបញ្ជានេះ និងបទបញ្ញត្តិច្បាប់ភូមិបាលដែលពាក់ព័ន្ធមួយចំនួនគួរយកទៅប្រើលើការដោះដូរដីណាដែលកើតឡើងក្រោយការអនុម័តច្បាប់ភូមិបាលឆ្នាំ២០០១ ។

៣៦- ករណីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងករណីមន្ទីរពេទ្យព្រះមុន្នីវង្សផ្តល់ជាឧទាហរណ៍ជាក់ស្តែងនូវរបៀបដែលការដោះដូរដី ឬការលក់ដូរដីប៉ះពាល់ដល់សិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពសមរម្យ ។

## ១- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

៣៧- នៅឆ្នាំ ១៩៨៤ ក្រសួងវប្បធមិបានចាត់តាំងបុគ្គលិកឱ្យទៅធ្វើការនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្នុងគោលបំណងឱ្យបុគ្គលិកទាំងនោះគ្រប់គ្រងសយនដ្ឋានរបស់ខ្លួន។ គ្រួសារដែលទទួលបានការអនុញ្ញាត បានចាកចោលផ្ទះរបស់ខ្លួនទៅរស់នៅលើដីរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ នៅពេលដែលមានការដោះដូរដីកើតឡើង គឺមាន៦០គ្រួសារ(ភាគច្រើនមានមេគ្រួសារជាសាស្ត្រាចារ្យរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ) កំពុងរស់នៅលើដីនោះ។ ក្នុងខែកុម្ភៈ ឆ្នាំ២០០៥ លោកម៉ុងឫទ្ធីដែលគេស្គាល់ថាជាអ្នកជំនួញដ៏ល្បីល្បាញក្នុងប្រទេសកម្ពុជា បានអះអាងពីការដែលខ្លួនទទួលបានការយល់ព្រមជាមួយក្រសួង វប្បធមិ និងវិចិត្រសិល្បៈ ដើម្បីសាងសង់បរិវេណសិល្បៈថ្មីនៅក្រៅក្រុងក្នុងខ័ណ្ឌឫស្សីកែវដែលមានចំងាយ៦គីឡូម៉ែត្រពីទីក្រុង ជាមួយ និងការដោះដូរសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (RUFA) ដែលមានទីតាំងនៅ ចំកណ្តាលទីក្រុងភ្នំពេញ ជិតពហុកីឡាដ្ឋានជាតិស្តាតចាស់។

៣៨- នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៥ សហគមន៏បានទទួលលិខិតជូនដំណឹងពីក្រុមហ៊ុន ម៉ុងឫទ្ធីគ្រុប សូមឱ្យពួកគេចាកចេញពីលំនៅដ្ឋាន ដោយទទួលបានសំណងមានកំរិត។ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៥ ក្រុមហ៊ុនបានបញ្ជូនកម្មករ និងកងការពារប្រដាប់ដោយអាវុធមកទីតាំងនេះ ទោះបីជាមានលិខិតរបស់គណៈរដ្ឋមន្ត្រីចុះថ្ងៃ ទី៩ខែកុម្ភៈ ឆ្នាំ២០០៥ ចែងថា ទីតាំងនេះនិងត្រូវប្រគល់ឱ្យទៅក្រុមហ៊ុនបាន លុះត្រាតែក្រុមហ៊ុនបានបញ្ចប់ការសាងសង់រួចរាល់នៅកន្លែងថ្មីក៏ដោយ ។ ក្រៅពីបញ្ហាសំណងពុំបានដោះស្រាយរួចផង កម្មកររបស់ក្រុមហ៊ុនបានចាប់ផ្តើមកាប់រំលំដើមឈើ។ នៅពេលដែលតំណាងសហគមន៏ព្យាយាមធ្វើអន្តរាគមន៏ អ្នកដឹកនាំបានគំរាមដាក់ពង្រាយកងសន្តិសុខប្រដាប់ដោយអាវុធ។ ក្នុងខែមេសា ក្រហ៊ុនម៉ុងឫទ្ធីគ្រុបបានយល់ព្រមផ្តល់ប្រាក់៧០០ដុល្លាអាមេរិកដល់សាស្ត្រាចារ្យម្នាក់ៗ ដែលទទួលរងប៉ះពាល់មានចំនួនជាង៤០០នាក់ ហើយយល់ព្រមផ្តល់ ២០០០ ទៅ ៤០០០ ដុល្លា ដល់គ្រួសារនិមួយៗ ដែលរស់នៅក្នុងសាលា។ យោលតាមការព្រមព្រៀង ប្រសិនបើក្រុមគ្រួសារយល់ព្រមរើចេញទៅរស់នៅកន្លែងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈថ្មី គេនឹងប្រគល់ជូនប័ណ្ណកម្មសិទ្ធិដី និងសុវត្ថិភាពកាន់កាប់ដល់គ្រួសារទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ ប័ណ្ណទាំងនោះពុំទាន់បានផ្តល់ឱ្យនៅឡើយទេ នៅពេលដែលរបាយការណ៏នេះកំពុងសរសេរ។ ក្រោមការគាបសង្កត់

និងវត្តមាននៃកងសន្តិសុខបំពាក់ដោយអាវុធនៅក្នុងកន្លែងនោះ ក្រុមគ្រួសារភាគច្រើនបានយល់ព្រមចាកចេញ ។ នៅក្នុងអំឡុងពេលទស្សនកិច្ចរបស់អ្នករាយការណ៍ពិសេសមានមួយគ្រួសារពុំទាន់ចាកចេញពីទីនោះ ។

៣៩- អំឡុងពេលទស្សនកិច្ចនៅកន្លែងនោះ អ្នករាយការណ៍ពិសេសបានសង្កេតឃើញថាអគារទាំងអស់ត្រូវបានកំទេច លើកលែងតែផ្ទះបីខ្នងប៉ុណ្ណោះ ។ កំទេចកំទីថ្មបាក់បែកត្រូវបានគេឈូសដាក់ព័ទ្ធជុំវិញលំនៅដ្ឋានរបស់គ្រួសារដែលមិនព្រមរើចេញ ។ ត្រាក់ទ័រប៊ូលដូស័រកំពុងឈូសឆាយដីនៅចម្ងាយតែពីបីម៉ែត្រពីច្រកចេញចូលនៃផ្ទះទាំងនោះ ។ ទាហ៊ានធ្វើសកម្មភាពជាកងសន្តិសុខរបស់ក្រុមហ៊ុនកំពុងឈរយាមកន្លែងនោះ ។ គ្រួសារទាំងនោះចេញចូលផ្ទះរបស់ខ្លួនតាមប្រហោងរបងដែលគេបានចោះ ។ អ្នករាយការណ៍ពិសេសបានទៅទស្សនាផងដែរកន្លែងដែលគ្រួសារទាំងនោះទៅតាំងទីលំនៅថ្មី ដែលស្ថិតនៅក្បែរទីតាំងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈថ្មី ។ គឺជាដីឡូត៍តូចៗមួយដែលមានទឹកដក់ស្ថិតនៅក្បែរមាត់បឹងបង្ហូរទឹក ។ គ្មានភ្លើង ទឹក ឬប្រព័ន្ធអនាម័យឡើយ ។ ពួកគេប្រើប្រាស់ទឹកបឹងនោះសំរាប់បោកគក់ និងធ្វើអនាម័យផ្សេងៗ ។ ក្រុមគ្រួសារខ្លះរស់នៅក្នុងតង់នៅឡើយ ខណៈដែលពួកគេកំពុងសាងសង់ផ្ទះថ្មីរបស់ខ្លួន ។

## ២- មន្ទីរពេទ្យព្រះមុន្នីវង្ស

៤០- ចាប់តាំងពីឆ្នាំ១៩៨៨ មក ដោយមានការអនុញ្ញាតពីអាជ្ញាធររដ្ឋាភិបាល បុគ្គលិកមន្ទីរពេទ្យព្រះមុន្នីវង្សប្រហែល៤០ នាក់ និងគ្រួសាររបស់ខ្លួនបានមករស់នៅក្នុងបរិវេណមន្ទីរពេទ្យនគរបាលនេះ ។ តាមសេចក្តីរាយការណ៍ ពីឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩៣ រដ្ឋាភិបាលបានឱ្យក្រុមគ្រួសារបុគ្គលិកប្រហែល១០០គ្រួសារថែមទៀតមករស់នៅទីនេះ ភាគច្រើនគឺមកពីជំរំជនភៀសខ្លួនព្រំដែនថៃ ។ ក្នុងពេលធ្វើរបាយការណ៍នេះ ចំនួនសរុបមានប្រហែល១៦៨គ្រួសារដែលកំពុងរស់នៅទីនោះ ដែលក្នុងនោះមានបុគ្គលិកមន្ទីរពេទ្យ នគរបាល និងសមាជិកគ្រួសាររបស់ពួកគេ ។ គ្រួសារទាំងនោះបានអភិវឌ្ឍលំនៅដ្ឋានរបស់ខ្លួន ធ្វើផ្លូវ ដាក់ប្រព័ន្ធលូបង្ហូរទឹក ដាក់ប្រព័ន្ធទឹកស្អាត និងតភ្ជាប់ប្រព័ន្ធអគ្គិសនី ។ ក្នុងឆ្នាំ២០០០ ក្រុមគ្រួសារទាំងនោះបានចងក្រងជាសហគមន៍ឈ្មោះ "សហគមន៍ព្រះមន្នីវង្ស អា បេ" ដែលបន្ទាប់មកត្រូវបានទទួលស្គាល់ដោយអាជ្ញាធរ ហើយបានទទួលរង្វាន់ជា លិខិតសសើរថាជា "សហគមន៍គំរូ" ពីសាលាក្រុង ។

៤១- ក្នុងខែកុម្ភៈឆ្នាំ២០០៥ ក្រសួងមហាផ្ទៃបានលក់ដូរដីមន្ទីរពេទ្យទៅឱ្យក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប សំរាប់ធ្វើការអភិវឌ្ឍន៍ឡើងវិញ។ គេពុំបានពិគ្រោះយោបល់ជាមួយគ្រួសារដែលពាក់ព័ន្ធទាំងនោះឡើយ។ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ក្រសួងមហាផ្ទៃបានចេញលិខិតជូនដំណឹងឱ្យអ្នករស់នៅទីនោះចាកចេញពីលំនៅដ្ឋាន និងចេញពីបរិវេណមន្ទីរពេទ្យនោះក្នុងរយៈពេល៣០ថ្ងៃ បើពុំនោះទេពួកគេនឹងត្រូវទទួលរងនូវការបណ្តេញចេញ។ ក្នុងពេលនោះ គេពុំបានធ្វើការបណ្តេញចេញទេ ក៏ប៉ុន្តែបន្ទាប់ពីនោះមកសហគមន៍នេះទទួលរងនូវការគំរាមកំហែងស្តីពីការបណ្តេញចេញជាច្រើនលើកច្រើនសារ។ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៥ តំណាងខាងក្រសួងមហាផ្ទៃបានចាត់ប្រជុំជាមួយនិងអ្នកភូមិចំនួន៤៨ នាក់ ដែលភាគច្រើនគឺជាមន្ត្រីនគរបាលរស់នៅក្នុងសហគមន៍ព្រះមុន្នីវង្ស អា បេ។ ក្រសួងបានផ្តល់ឱ្យគ្រួសារនីមួយៗនូវដី១ឡូត៍ ដែលស្ថិតនៅចំងាយប្រហែល២០គីឡូម៉ែត្រពីទីក្រុង ហើយគ្មានសេវាកម្មចាំបាច់អ្វីទាំងអស់។ តែការចរចានេះពុំបានសំរេចឡើយ។ តំណាងសហគមន៍បានរាយការណ៍ថា មានការគំរាមគំហែងមកលើពួកគាត់។ គេបានប្រាប់ពួកគាត់ថា ប្រសិនណាបើពួកគាត់មិនព្រមទទួលយកទេ ពួកគាត់នឹងបាត់បង់តំណែងជាមន្ត្រីរាជការ ឬពួកគាត់នឹងត្រូវទទួលរងនូវការបណ្តេញចេញដោយប្រើកំលាំង។

៤២- យោលទៅតាមច្បាប់ភូមិបាល ឆ្នាំ២០០១ គឺច្បាស់ណាស់ថា មន្ទីរពេទ្យជាសម្បត្តិសាធារណៈរបស់រដ្ឋ ដូច្នេះ ហើយយោលទៅតាមច្បាប់គឺមិនអាចលក់ ដោះដូរ ឬលក់ដូរបានឡើយ។ ទន្ទឹមនឹងគ្នានេះដែរ រដ្ឋាភិបាលមានកាតព្វកិច្ចត្រូវតែគោរពការសន្យារបស់ខ្លួនចំពោះប្រជាពលរដ្ឋដែលបានចូលមករស់នៅកន្លែងនោះជាច្រើនឆ្នាំកន្លងមកនេះ ហើយមិនអាចប្រកែកបានឡើយ ដែលខ្លួនបានអនុញ្ញាតឱ្យពួកគាត់ចូលមករស់នៅទីនោះ។ ដូច្នេះហើយ រដ្ឋាភិបាលត្រូវផ្តល់នូវដំណោះស្រាយមួយដល់ប្រជាពលរដ្ឋដែលរស់នៅលើដីមន្ទីរពេទ្យនេះ មិនឱ្យអាក្រក់ជាងស្ថានភាពរបស់ពួកគាត់នាពេលបច្ចុប្បន្ននេះឡើយ។

៤៣- ក្នុងអំឡុងពេលទស្សនកិច្ចរបស់លោកនៅកន្លែងនោះ អ្នករាយការណ៍ពិសេសបានកត់ត្រាទុកនូវបំណងរបស់ពលរដ្ឋទាំងនោះ គឺពួកគាត់ចង់រស់នៅទីនោះ និងអភិវឌ្ឍឱ្យប្រសើរឡើងនូវលំនៅដ្ឋានរបស់ខ្លួនតាមរយៈការចែករំលែកដី។ អ្នករាយការណ៍ពិសេសគាំទ្រចំពោះសំណើនេះ ដោយហេតុថា គ្រួសារដែលទទួលរងការប៉ះពាល់ទាំងនោះបានរស់នៅទីនោះតាំងពីចុងឆ្នាំ ១៩៨០ មកម្ល៉េះ។

## ខ- ការបណ្តេញចេញដោយបង្ខំ

៤៤- អ្នករាយការណ៍ពិសេសប្រមូលបានសាក្សីកម្មជាច្រើនពីសហគមន៍ដែលទទួលរងនូវការគំរាមគំហែងពីការបណ្តេញចេញដោយបង្ខំ និងគ្រួសារដែលបាត់បង់ជំរកដោយសារការបណ្តេញចេញនេះ។ តាមរយៈសាក្សីកម្ម និងឯកសារដែលប្រមូលបាន អ្នកតំណាងពិសេសអាចសង្កេតឃើញថា ជាធម្មតាគេតែងតែយកការបណ្តេញចេញជាជម្រើសទីមួយ និងជាជម្រើសតែមួយគត់ ដែលមិនមែនជាដំណោះស្រាយចុងក្រោយ។ ករណីជាច្រើនបានបង្ហាញច្បាស់ថា ពុំមានការចូលរួម ព្រមទាំងការពិគ្រោះយោបល់ឱ្យបានគ្រប់គ្រាន់ឡើយ។ ក្នុងករណីមួយចំនួនដែលមានការចរចាកើតឡើងនោះ ដំបូងបំផុតដែលគេលើកយកមកពិភាក្សាគឺសំណង និងការផ្លាស់ប្តូរទីជំរក។ តាមការអះអាងបានអោយដឹងថា ពុំមានការជូនដំណឹងជាមុន ឬទំនាក់ទំនងជាផ្លូវការណាមួយធ្វើឡើងនៅមុនពេលអនុវត្តបទបញ្ជាបណ្តេញចេញ ដែលចេញដោយតុលាការឡើយ។

៤៥- ពាក់ពន្ធ័លើករណីនេះ អ្នករាយការណ៍ពិសេសសូមទាញចំណាប់អារម្មណ៍លើតួនាទីដ៏សំខាន់របស់ប្រព័ន្ធតុលាការក្នុងជំលោះលំនៅដ្ឋាន។ យោងតាមសាក្សីកម្មដែលទទួលបាន នីតិវិធីស៊ើបអង្កេតដែលអនុមត័ដោយតុលាការ ដើម្បីធានាធម្មានុរូប និងនីត្យានុកូលភាពនៃប័ណ្ណកម្មសិទ្ធិ ត្រូវបានគេសង្កេតឃើញថាធ្វើមិនបានគ្រប់ជ្រុងជ្រោយឡើយ។ ផលវិបាកនោះគឺថា សេចក្តីសំរេចរបស់តុលារការមានទំនោឱ្យអ្នកដែលមានប័ណ្ណកម្មសិទ្ធិខុសច្បាប់ឈ្នះ និងនាំឱ្យខូចប្រយោជន៍ដល់គ្រួសារដែលអាចទទួលផលប្រយោជន៍ពីបទបញ្ញត្តិរបស់ច្បាប់ភូមិបាល ឆ្នាំ២០០១ ពាក់ព័ន្ធទៅនឹងសិទ្ធិលើកម្មសិទ្ធ ដែលកើតចេញពីការកាន់កាប់ និងភោគៈលើដីជារៀងរហូតមក។

៤៦- អង្គការដែលធ្វើការផ្នែកវិវាទលំនៅដ្ឋានបានបញ្ជាក់ថា និន្នាការមួយផ្សេងទៀតគឺៈ នៅពេលដែលរឿងក្តីរដ្ឋប្បវេណីត្រូវបានលើកលែងការចោទប្រកាន់ ហើយផ្ទេររឿងក្តីនោះទៅឱ្យគណៈកម្មការសុរិយោដី ដើម្បីចាត់ការបន្តនោះ គឺមានសំណុំរឿងព្រហ្មទណ្ឌប្តឹងលើដើមបណ្តឹងដដែលនោះ ដោយផ្អែកលើមាត្រា២៤៧នៃច្បាប់ភូមិបាល អំពីការប៉ះពាល់កម្មសិទ្ធិ បើទោះបីជាកម្មសិទ្ធិនោះកំពុងត្រូវបានដោះស្រាយដោយអាជ្ញាធរសុរិយោដីក៏ដោយ។

៤៧- បច្ចុប្បន្ន នៅភ្នំពេញមានកន្លែងតាំងទីលំនៅថ្មីជុំវិញទីក្រុងនេះចំនួន១៩ កន្លែង។ ចម្ងាយពីកន្លែងថ្មីមកទីក្រុង ជាទូទៅមានចម្ងាយប្រហែលពី១០ ទៅ១៥ គីឡូម៉ែត្រ។ ចម្ងាយឆ្ងាយពីកន្លែងធ្វើការគឺជាបញ្ហាដ៏ធំបំផុតសំរាប់អ្នកដែលរើទៅនៅកន្លែងថ្មី: អ្នកទាំងនោះបានរាយការណ៍ថា ពួកគាត់បាត់បង់ចំណូលប្រហែល២០ ភាគរយ បន្ទាប់ពីពួកគាត់មកតាំងទីលំនៅថ្មីនៅជាយក្រុងនេះ។ ដោយយោលទៅតាមចម្ងាយនិងកាលៈទេសៈបុគ្គល នៅកន្លែងខ្លះចំណូលរបស់ពួកគាត់ធ្លាក់ចុះពី៥០ ទៅ៧០ ភាគរយ ដោយសារការកើនតម្លៃដឹកជញ្ជូនតម្រូវឱ្យពួកគាត់ទទួលការងារដែលមានតម្លៃទាបនៅកន្លែងទីតាំងថ្មីនោះ ឬមកពីអត់ការងារធ្វើ (មជ្ឈ-មណ្ឌលធនធានសំរាប់ទីក្រុង ២០០២, ២៦,៣៧)។ បញ្ហាចំបងផ្សេងទៀតនោះគឺការខ្វះខាតសេវាកម្មចាំបាច់មួយចំនួន ជាពិសេស ទឹក ភ្លើង និងអនាម័យ។ ពួកគាត់ទាំងនោះត្រូវប្រើសេវារបស់ឯកជនដែលមានតម្លៃខ្ពស់ ទាំងនេះនាំឱ្យចំណូលរបស់ពួកគាត់ធ្លាក់ចុះ។ ភាគច្រើនចំពោះពួកគាត់ដែលមកតាំងទីលំនៅថ្មីនោះ គេពុំបានធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដូចដែលបានសន្យាមុនពេលផ្លាស់មកឡើយ។

៤៨- ចុងក្រោយនេះ អ្នករាយការណ៍ពិសេសសូមទាញចំណាប់អារម្មណ៍លើរបាយការណ៍អំពីការគំរាមគំហែង និងបំភិតបំភ័យ ក៏ដូចជាការប្រើអំពើហឹង្សាលើរាងកាយ នៅមុន ឬនៅពេលកំពុងធ្វើការបណ្តេញចេញដោយបង្ខំ។ ករណីគំរាមកំហែង និងបំភិតបំភ័យ ធ្វើឡើងដោយអាជ្ញាធរមូលដ្ឋាន និងអ្នកអភិវឌ្ឍឯកជននាំឱ្យមានការចរចា ការរើទៅកន្លែងថ្មី ឬតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្ត ចំណុចត្រង់នេះបានទាញចំណាប់អារម្មណ៍ដល់អ្នករាយការណ៍ពិសេស ម្តងហើយម្តងទៀត។ ភាគច្រើន ករណីបែបនេះ គឺមានការចូលពាក់ព័ន្ធពីកងទ័ព និងកងកំលាំងនគរបាលប្រដាប់អាវុធ។ ចំពោះករណីប្រើអំពើហឹង្សាលើរាងកាយ ហាក់បីដូចជាកើតមានច្រើននៅតាមខេត្ត ជាពិសេសនៅតាមតំបន់ដាច់ស្រយាល និងជនបទ។

៤៩- អំឡុងពេលបេសកកម្មរបស់លោក អ្នករាយការណ៍ពិសេសបានធ្វើទស្សកិច្ចនៅភូមិក្បាលស្ពាន និងកោះពេជ្រ ដែលករណីទាំងពីរនេះបានបង្ហាញយ៉ាងច្បាស់នូវស្ថានការណ៍ដូចដែលបានរៀបរាប់ខាងលើ។

## ១- កោះពេជ្រ

៥០- កោះពេជ្រ គឺជាកោះមួយស្ថិតក្នុងទន្លេបាសាក់ ដែលមានទំហំដីប្រមាណ ៦៨ ហិកតា ចំកណ្តាលក្រុងភ្នំពេញ។ ក្នុងឆ្នាំ២០០៤ អាជ្ញាធរមូលដ្ឋានជាមួយនិងក្រុមហ៊ុនអភិវឌ្ឍន៍ 7NG បានចាប់ផ្តើមធ្វើការគាប

សង្កត់អ្នកភូមិឱ្យចាកចេញពីដីកោះនេះ ដែលគេនឹងធ្វើឱ្យមានស្ថិរភាព និងអភិវឌ្ឍកោះនេះឡើងវិញ ឱ្យទៅជា "ទីក្រុងរណបមួយ" ។ ក្រុមហ៊ុនសាជីវកម្ម វិនិយោគទុនក្រៅប្រទេសកម្ពុជា (OCIC) តាមរយៈធនាគារកាណាឌីយ៉ា គឺជាក្រុមហ៊ុនធំក្នុងការបណ្តាក់ទុនលើគម្រោងនេះ។ ក្នុងឆ្នាំ ២០០៤ អ្នកភូមិកោះពេជ្រប្រហែល ៣០០ គ្រួសារ ដែលភាគច្រើនជាអ្នកស្រែចំការ បានរស់នៅទីនោះតាំពីឆ្នាំ១៩៨០ ត្រូវបានគេផ្តល់ឱ្យប្រាក់មួយចំនួន (២ ដុល្លាអាមេរិក ក្នុងមួយម៉ែត្រការ៉េ) ហើយចេញទៅតាំងទីលំនៅថ្មីនៅដីជាយក្រុងក្នុងខេត្តកណ្តាល។ យោងតាមរបាយការណ៍ដែលអាចជឿជាក់បាន គេបានធ្វើការគំរាមកំហែង និងបំភិតបំភ័យដោយពាក្យសំដី និងកាយវិការដល់អ្នកស្រុកឱ្យទទួលយកការចាត់ចែងនេះ។ ចំនួនដែលផ្តល់ឱ្យ មានតម្លៃទាបឆ្ងាយណាស់បើតាមការប៉ាន់ប្រមាណពីតម្លៃទីផ្សារសេរី ហើយទីតាំងលំនៅដ្ឋានថ្មីដែលបានផ្តល់ឱ្យនោះគឺមិនសមស្របទេ។ ដោយសារមានការភ័យខ្លាច និងការប្រឈមជាមួយការគំរាមកំហែង គ្រួសារជាច្រើនបានចាកចេញ ប៉ុន្តែមានប្រហែល១០០គ្រួសារបានសំរេចចិត្តថារស់នៅជាបន្តរទៀត។ នៅថ្ងៃទី ៦ធ្នូ ២០០៤ សាលាក្រុងបានចេញបទបញ្ជបណ្តេញចេញគ្រួសារទាំងនេះ គឺឱ្យចាកចេញក្នុងរយៈពេល៣០ថ្ងៃ។ បើតាមសាលាក្រុង កោះពេជ្រគឺជាទ្រព្យសម្បត្តិរដ្ឋ ហើយអ្នកភូមិគ្មានសិទ្ធិកាន់កាប់ដីនោះស្របច្បាប់ឡើយ។ គ្រួសារទាំងនោះប្រឆាំងយ៉ាងដាច់ខាតជាមួយនឹងការអះអាងនេះ។ ការចរចាដោយបង្ខំរវាងតំណាងក្រុមគ្រួសារជាមួយសាលាក្រុងបានចាប់ផ្តើមឡើងក្នុងខែមករា ឆ្នាំ២០០៥។ កាលកំណត់នៃការបណ្តេញចេញបានកន្លងទៅដោយពុំមានហេតុការណ៍អ្វីកើតឡើងឡើយ ក៏ប៉ុន្តែមានហេតុការណ៍នៃការបំភិតបំភ័យពីអាជ្ញាធរកើតមានឡើងដូចជាការដាក់កងរាជអាវុធហត្ថលើកោះ និងការដកហូតយកទូកដរចំលងដែលសំរាប់ឆ្លងពីដីកោះមកដីគោក។

៥១- ក្នុងខែកក្កដា ឆ្នាំ២០០៥ បន្ទាប់ពីមានការចរចាដោយបង្ខំ អ្នកស្រុកដែលនៅសល់ជាច្រើនជាពិសេសអ្នកដែលរស់នៅចុងកោះខាងត្បូងបានយល់ព្រមទទួលការផ្តល់សំណងដែលមានតម្លៃទាបជាងទីផ្សារ ហើយបានចាកចេញពីកោះនោះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្រុកដែលរស់នៅដើមកោះផ្នែកខាងជើង ដែលមានឯកសារអះអាងខាងផ្លូវច្បាប់រឹងប៉ឹងលើដី បន្តរស់នៅតទៅទៀត។ នៅក្នុងខែសីហា សាលាក្រុងបានដាក់បណ្តឹងពីរ ដោយចោទអ្នកស្រុកទាំងនេះថាកាន់កាប់ដីកោះនេះដោយខុសច្បាប់ ហើយស្នើឱ្យតុលាការចេញដីកាកិច្ចការប្រញាប់ ដើម្បីធ្វើការបណ្តេញអ្នកភូមិដែលនៅសល់ចេញពីដីកោះ។ នៅឯតុលាការ តំណាងក្រុមគ្រួសារបានស្នើសុំឱ្យតុលាការបើកសវនាការដោយបើកចំហរជាសាធារណៈ ដើម្បីឱ្យក្រុមគ្រួសារដែលទទួល

រងការប៉ះពាល់អាចចូលរួមស្តាប់បាន។ តែចៅក្រមបានធ្វើការបដិសេធ ហើយតំណាងអ្នកស្រុកបានប្រឆាំងនឹងការបដិសេធនេះ ដោយដើរចេញពីបន្ទប់សវនាការ។ ចៅក្រមបានចេញដីកាកិច្ចការប្រញាប់ដោយកំបាំងមុខ។ ការវិភាគផ្លូវច្បាប់បានរិះគន់ការប្រើប្រាស់នីតិវិធីផ្លូវច្បាប់ទៅលើអ្នកស្រុក ដោយមានមូលហេតុបីយ៉ាង។ ទីមួយ គឺតុលាការពុំមានយុត្តាធិការក្នុងការកាត់ក្តីនេះឡើយ។ ក្រោមច្បាប់កម្ពុជា មានតែគណៈកម្មការសុរិយោដីតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការសំរេចរឿងក្តីនេះ ពីព្រោះដីដែលកំពុងមានជំលោះពុំទាន់មានចុះបញ្ជីសុរិយោដីនៅឡើយ។ ទីពីរ ការប្រើប្រាស់ដីកាកិច្ចការប្រញាប់ ដើម្បីធ្វើការបណ្តេញគ្រួសារទាំងនះចេញពីដីកោះ គឺផ្ទុយទាំងស្រុងទៅនឹងសេចក្តីណែនាំរបស់តុលាការកំពូលស្តីពីការចេញដីកាកិច្ចការប្រញាប់។ ចុងក្រោយនេះ ដោយហេតុថាគ្រួសារទាំងនេះមានឯកសារអះអាងតាមផ្លូវច្បាប់រឹងប៉ឹងក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ ផងនោះ ការសំរេចរបស់តុលាការនេះនាំមកនូវការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ពួកគាត់ដែលធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាលកម្ពុជា។

៥២- អំឡុងពេលសរសេររបាយការណ៍នេះ គ្រួសារទាំងអស់បានយល់ព្រមចាកចេញ លើកលែងតែប្រជាពលរដ្ឋបីគ្រួសារប៉ុណ្ណោះ ដែលទាមទារសំណង ២៥ ដុល្លាអាមេរិកក្នុងមួយម៉ែត្រការ៉េ។ ភាគច្រើននៃគ្រួសារទាំងនោះទទួលបានពី ១០ ទៅ១២ ដុល្លាអាមេរិកក្នុងមួយម៉ែត្រការេ ដែលទាបជាងតំលៃទីផ្សារ ប៉ុន្តែបានច្រើនជាងចំនួនដែលគេបានផ្តល់ឱ្យកាលពីដើមដំបូង។ ទោះជាយ៉ាងណា អ្នករាយការណ៍ពិសេសបានទទួលរបាយការណ៍ថា សាលាក្រុង និងធានាគារកាណាឌីយ៉ាបានស្នើសុំឱ្យគ្រួសារនីមួយៗចុះហត្ថលេខាលើកិច្ចសន្យា ដោយទទួលស្គាល់ថាដំណោះស្រាយដែលបានព្រមព្រៀងគ្នារួចហើយនេះ មិនមែនដើម្បីយកធ្វើជាលំនាំនៃចំនួនសំរាប់ធ្វើជាការទូទាត់សំណងឡើយ។ អ្នករាយការណ៍ពិសេសសង្ឃឹមថា ការព្រមព្រៀងដ៏សំខាន់នឹងកើតមានឡើងចំពោះគ្រួសារដែលនៅសេសសល់ ដោយការគោរពតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

៥៣- ក្រៅពីកិច្ចព្រមព្រៀងថ្មីៗ ដោយគោរពចំពោះអ្នកស្រុកកោះពេជ្រ ហើយនិងការប្រឹងប្រែងរបស់មន្ត្រីសាលាក្រុងក្នុងការអភិវឌ្ឍន៍គោលនយោបាយគាំទ្រជនក្រីក្ររបស់សាលាក្រុងភ្នំពេញ គឺថាករណីកោះពេជ្រនេះ គឺជាឧទាហរណ៍ដ៏ល្អបំផុតនៃអំពើពុករលួយដែលកំពុងកើតមាននៅក្នុងគំរោងអភិវឌ្ឍន៍នានាក្នុងទីក្រុង។ គំរោងនេះហាក់បីដូចជាត្រូវគេបញ្ជាដោយមានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ហើយនិងកាលានុវត្តន៍នយោ

បាយ។ ដូចដែលបានពន្យល់ខាងលើ តុលាការក្រុងភ្នំពេញប្រើប្រាស់ច្បាប់មិនត្រឹមត្រូវ ដោយប្រកាន់ខាងអ្នកមានអំណាច។ ដោយគ្មានការពិគ្រោះយោបល់ ជាលទ្ធផលសហគមន៍តែងទទួលរងការប្តូរទីតាំងដោយបង្ខំតាមរយៈការប្រើប្រាស់ការគំរាមកំហែង និងការបំភិតបំភ័យ។ អ្នករាយការណ៍ពិសេសសូមឆ្លៀតឱកាសនេះដើម្បីបង្ហាញពីការគាំទ្ររបស់ខ្លួន និងសូមថ្លែងអំណរគុណដល់គម្រោងតស៊ូមតិតាមផ្លូវច្បាប់ដើម្បីផលប្រយោជន៍សាធារណៈ របស់មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC-PILAP) អង្គការក្រៅរដ្ឋាភិបាលនានា និងបុគ្គលិករបស់អង្គការទាំងនោះ ដែលបានធ្វើកិច្ចការនេះ តាំងពីខែមករា ឆ្នាំ២០០៥ កន្លងមក។

## ២- ក្បាលស្ពាន

៥៤- ជំលោះដីធ្លីនេះកើតមានតាំងពីឆ្នាំ១៩៩៨ មក រវាងសហគមន៍ដែលមាន២១៨ គ្រួសារដែលអ្នកខ្លះបានមករស់នៅលើដីនេះតាំងពីឆ្នាំ១៩៩៧ ហើយអ្នកខ្លះបានទិញដីនេះពីអ្នកផ្សេងទៀតដែលបានរស់នៅទីនោះពីឆ្នាំ១៩៩៧ ជាមួយនិងមេភូមិដែលបានប្តឹងទាមទារជាម្ចាស់ដី នៅតុលាការខេត្តបន្ទាយមានជ័យ។ តុលាការខេត្តបានកាត់ក្តីអោយមេភូមិជាម្ចាស់កម្មសិទ្ធិ ដោយផ្អែកលើប័ណ្ណកម្មសិទ្ធិ ដែលគេអះអាងថាអសុពលភាព។ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០១ សាលាឧទ្ធរណ៍បានតំកល់សេចក្តីសំរេចរបស់តុលាការដំបូង ទោះបីមានការរអ៊ូរទាំថាការកាត់ក្តីនោះមានភាពមិនប្រក្រតីជាច្រើនក៏ដោយ។ បន្ទាប់ពីសាលាឧទ្ធរណ៍សំរេចសេចក្តីមក មានការប៉ុនប៉ងបីដង ដើម្បីបណ្តេញសហគមន៍ចេញពីដីនោះ។ ការប៉ុនប៉ងចុងក្រោយធ្វើឡើងនៅថ្ងៃទី ២១ ខែមិនា ឆ្នាំ២០០៥ ដោយមានកងរាជអាវុធហត្ថ នគរបាលស្រុក និងខេត្ត ប្រមាណជា១២០ នាក់ចូលរួមធ្វើការហ៊ុំព័ទ្ធភូមិ។ ជាលទ្ធផលនៃកិច្ចសហប្រតិបត្តការនេះ មានអ្នកភូមិ៥នាក់ស្លាប់ និងរងរបួសជាច្រើន ផ្ទះត្រូវបានដុតបំផ្លាញ ទ្រព្យសម្បត្តិឯកជនជាច្រើនត្រូវបានបំផ្លាញ។ អ្នកភូមិបានអះអាងថា គេពុំបានទទួលព័ត៌មានជាផ្លូវការពីការបណ្តេញចេញនេះទេ។ ក្រោយពីផ្ទះរបស់ខ្លួនត្រូវបានគេបំផ្លាញអស់ អ្នកភូមិបានរើទៅនៅក្បែរនោះ ប៉ុន្តែដោយហេតុថា ពុំមានការផ្តល់លំនៅដ្ឋានដែលអាចទទួលយកបាននោះ នៅក្នុងខែមេសារ អ្នកភូមិបានត្រឡប់ចូលមករស់នៅភូមិក្បាលស្ពានវិញ។ គេបានផ្តល់ដីសំរាប់សង់លំនៅដ្ឋានថ្មី នៅចំងាយប្រមាណ៤គីឡូម៉ែត្រពីភូមិក្បាលស្ពាន តែអ្នកភូមិបានបដិសេធមិនទទួលយក។ បើតាមអ្នកភូមិបានឱ្យដឹងថា តំបន់ដែលផ្តល់ឱ្យពួកគាត់ស្ថិតនៅឆ្ងាយពីព្រំដែនថៃ គឺឆ្ងាយពីកន្លែងដែលពួកគាត់រកទទួលទានប្រចាំថ្ងៃ។

៩៥- អាជ្ញាធរមួយចំនួនដែលពាក់ព័ន្ធក្នុងការបណ្តេញចេញនៅក្នុងខែមីនាឆ្នាំ២០០៥ ដែលបណ្តាលឱ្យប្រជាពលរដ្ឋ៥នាក់ស្លាប់ ត្រូវបានគេបញ្ជូនទៅតុលាការ ក៏ប៉ុន្តែក្នុងខែសីហាឆ្នាំ២០០៥ តុលាការខេត្តបាត់ដំបងបានលើកលែងការចោទប្រកាន់ដោយថា ខ្វះភស្តុតាង។ អ្នករាយការណ៍ពិសេសបានសង្កេតឃើញថាពុំមានការឆ្លើយតបឱ្យបានគ្រប់គ្រាន់ពីរដ្ឋាភិបាល ក្នុងការស្វែងរកអ្នកដែលត្រូវទទួលខុសត្រូវ និងឆ្លើយតបទៅនឹងដំណោះស្រាយ ដោយមានប្រសិទ្ធិភាពដែលអ្នកភូមិមានសិទ្ធិទទួលបានឡើយ។ ករណីនេះបានបង្ហាញឱ្យឃើញផងដែរ អំពីការដែលតុលាការស្ថិតក្រោមបញ្ជារបស់នរណាម្នាក់ ហើយតម្រូវឱ្យមានការស៊ើបអង្កេតមួយដែលឯករាជ្យ។ ករណីនេះកំពុងស្ថិតនៅសាលាឧទ្ធរណ៍ ហើយបើតាមដំណឹងពីសារព័ត៌មាន អគ្គព្រះរាជអាជ្ញារបស់សាលាឧទ្ធរណ៍នឹងធ្វើការបើកសវនាការឡើងវិញ ហើយអ្នករាយការណ៍ពិសេសនិងសូមស្វាគមន៍ដល់ការបើកសវនាការឡើងវិញនេះ។

## គ- ភ្នំពេញ (២០០០-២០០៥)

៩៦- ស្ថានភាពលំនៅដ្ឋាននៅទីក្រុងភ្នំពេញប្រហាក់ប្រហែលគ្នាទៅនឹងទីក្រុងដទៃទៀតនៅក្នុងតំបន់ដែរ។ អត្រាកំណើននៃប្រជាពលរដ្ឋ និងការរីកចំរើនផ្នែកសេដ្ឋកិច្ចអាចប្រៀបធៀបបានទៅនឹងទីក្រុងហាណូយដែរ។ ក្នុងឆ្នាំ២០០៤ ភ្នំពេញមានប្រជាពលរដ្ឋ ១,៣១៣,៨៥១ នាក់ បើប្រៀបធៀបទៅឆ្នាំ ១៩៩៨ មាន ១,០៣៩,៦០៧ នាក់។ ដោយផ្អែកលើការវាយតម្លៃឡើងវិញ អំពីការប៉ាន់ប្រមាណស្ថិតិប្រជាពលរដ្ឋប្រទេសកម្ពុជា ឆ្នាំ១៩៩៨-២០២០ ដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនោះ គឺនៅក្នុងឆ្នាំ២០២០ ចំនួនប្រជាពលរដ្ឋនៅក្នុងរាជធានីនឹងមានចំនួន១០,៥ ភាគរយនៃចំនួនប្រជាពលរដ្ឋទាំងមូលក្នុងប្រទេសកម្ពុជា បើប្រៀបធៀបទៅនឹងឆ្នាំ២០០៨ មាន ៩,៨ ភាគរយ ហើយ ៨,៥ ភាគរយ ក្នុងឆ្នាំ១៩៩៨។ ការប៉ាន់ប្រមាណចំពោះទេសន្តរប្រវេសន៍ចូលទីក្រុងភ្នំពេញ មានប្រមាណ២១,៨៣៤ នាក់ក្នុងមួយឆ្នាំ[៣]។ ការវិភាគដំបូងដោយមន្ត្រីសាធារណៈ និងសកម្មជនសេដ្ឋកិច្ច គឺប្រហាក់ប្រហែលគ្នាទៅនឹងទីក្រុងបាងកកកាលពីទសវត្សឆ្នាំ១៩៧០ និងទីក្រុងកូឡាឡាំពួរឆ្នាំ១៩៨០ : ភាពទ្រុឌទ្រោមនៃវិស័យសាធារណៈ និងភាពទន់ខ្សោយនៃបទបញ្ញត្តិស្តីពីទីផ្សារដីធ្លីនិងអចលនវត្ថុ កិច្ចព្រមព្រៀងតុណ្ហីរវាងសកម្មជនសេដ្ឋកិច្ច និងរដ្ឋបាលសាធារណៈ[៤]។ បញ្ហាដ៏ធំនោះគឺថា សកម្មជនអ្នកនយោបាយ និងសកម្មជនសេដ្ឋកិច្ចជាអ្នកឱកាសនិយមដ៏ចំបងលើដីធ្លី និងអចលនវត្ថុ។

ដូច្នេះហើយ វាបាននាំឱ្យមានការពិបាកក្នុងការសំរេចគោលដៅប្រកបដោយចិរភាពសំរាប់ការអភិវឌ្ឍន៍ទីក្រុង។ ប្រជាពលរដ្ឋក្រីក្រជាជនរងគ្រោះដំបូងគេបង្អស់ដោយការអនុវត្តន៍ដែលគួរឱ្យសង្ស័យនេះ។

៥៧- ការអភិវឌ្ឍន៍ជាវិជ្ជមានខ្លះក្នុងទសវត្សរ៍ឆ្នាំ១៩៩០ បានរាំងស្ទះដោយភ្លើងឆេះផ្ទះរបស់សហគមន៍ធំៗមួយចំនួនរស់នៅ ក្នុងឆ្នាំ២០០០ និង ២០០១ គឺនៅបាសាក់និងនៅលើដំបូល ប្លុកតាន់ប៉ា ក្នុងឆាំ២០០២។ ព្រឹត្តការណ៍ជាយុទ្ធសាស្រ្តនេះបាននាំមកនូវការប្រកាសជាសាធារណៈនៃការផ្លាស់ប្តូរគោលនយោបាយដ៏ធំមួយ ដោយលោកនាយរដ្ឋមន្រ្តី កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៣ មុនពេលបោះឆ្នោតជាតិ ឆ្នាំ២០០៣។ នៅក្នុងឆ្នាំ២០០៣ សហព័ន្ធសាមគ្គីភាពសហគមន៍អ្នកក្រីក្រក្នុងទីក្រុងបានធ្វើការប៉ាន់ប្រមាណថា មានសហគមន៍ក្រីក្រចំនួន ៥៦៩ ស្មើនឹង ៦២.២៤៩ ខ្នងផ្ទះ (៣៧៤.៨៣៦ នាក់) ដែលកំពុងរស់នៅក្នុងក្រុងភ្នំពេញ ស្មើនឹង៣៥ ភាគរយ នៃចំនួនប្រជាពលរដ្ឋទាំងមូល នៅក្នុងទីក្រុងភ្នំពេញ។ លោកនាយករដ្ឋមន្រ្តីបានប្រកាសគោលនយោបាយក្នុងការផ្តល់សិទ្ធិកាន់កាប់ដី និងជួយសហគមន៍ក្រីក្រឱ្យអភិវឌ្ឍនៅនិងកន្លែង១០០សហគមន៍ក្នុងមួយឆ្នាំ នៅរយៈពេល៥ឆ្នាំខាងមុខ រហូតដល់សហគមន៍អ្នកក្រីក្រក្នុងទីក្រុងទទួលបានសិទ្ធិកាន់កាប់ដីធ្លី និងទទួលបានសេវាកម្មចាំបាច់ផ្សេងៗ។ តាំងពីការប្រកាសដ៏មានសារសំខាន់របស់លោកនាយករដ្ឋមន្រ្តីមក គឺគ្មានកម្មវិធីជាប្រព័ន្ធ និងជាដុំកំភួនដើម្បីដោះស្រាយការអភិវឌ្ឍន៍តំបន់ក្រីក្រនៅក្រុងភ្នំពេញឡើយ។ ការបាត់បង់ឱកាសដ៏សំខាន់នេះ គឺការផ្តល់សិទ្ធិកាន់កាប់ដីដល់គ្រួសារក្រីក្ររាប់ពាន់គ្រួសារនោះ។ មានការអភិវឌ្ឍន៍តូចៗ ដូចជាគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំឱ្យមានក្រុមសន្សំប្រាក់ (តាមរយៈគម្រោងមួយចំនួន រួមមានអង្គការលំនៅដ្ឋានរបស់ អង្គការសហប្រជាជាតិ (UN-Habitat ) និងមូលនិធិអភិវឌ្ឍន៍ជនក្រីក្រក្នុងទីក្រុង (UPDF) ក៏ប៉ុន្តែពុំមានអ្វីជាដុំកំភួនដែលធ្វើឱ្យមានសិទ្ធិលើដីធ្លីជាផ្លូវការឡើយ។ ម្យ៉ាងទៀត គោលនយោបាយ "អភិវឌ្ឍន៍នៅនឹងកន្លែង" គួរតែវាយតំលៃដោយផ្អែកទៅលើចំនួនសហគមន៍ដែលមានការអន់ថយដែលកើតឡើងដោយការបណ្តេញចេញដោយបង្ខំ និងការផ្លាស់ទីលំនៅ និងការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្ត។

៥៨- នៅក្នុងខែកក្កដា សារព័ត៌មានបានរាយការណ៍ថា ការសាងសង់នៅទីក្រុងភ្នំពេញមានការកើនឡើងយ៉ាងច្រើន។ ក្នុងឆ្នាំ២០០៤ មានការដ្ឋានសំណង់ចំនួន៩១១ កន្លែងត្រូវបានគេអនុញ្ញាតឱ្យ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០០ មានតែ ៦៧១ ការដ្ឋានប៉ុណ្ណោះ។ ក្នុងឆ្នាំ២០០៤ មានការសាងសង់ផ្ទះថ្មីចំនួន ៨.៨៧៩

ខ្នង ដែលគេបានអនុញ្ញាតឱ្យសាងសង់ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០០ គឺមានតែ១.១៨២ ខ្នងប៉ុណ្ណោះ[៥] ។ ដោយសារដីធ្លីនិងអចលនវត្ថុ ក្លាយជាផ្នែកមួយនាំមុខខាងការវិនិយោគទុនជាងផ្នែកទេសចរណ៍ និងឧស្សាហកម្មនោះ រលកថ្មីនៃការជួញដូរដីធ្លីបានចាប់ផ្តើមជះឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើតម្លៃផ្ទះ។

៥៩- ដូច្នេះហើយជំលោះដីធ្លីកាន់តែកើនឡើង ហើយទិដ្ឋភាពនៃការរំលោភសិទ្ធិខាងលំនៅដ្ឋាន និងការបណ្តេញចេញដោយបង្ខំនូវក្រុមប្រជាពលរដ្ឋដែលងាយទទួលរងគ្រោះ ជាពិសេសអ្នកក្រីក្រក្នុងទីក្រុង នឹងកើនឡើង។ ក្នុងឆ្នាំ២០០០ ដល់ឆ្នាំ ២០០៥ មាន៦.៨១០ គ្រួសារ ត្រូវបានគេបណ្តេញចេញដោយបង្ខំពីទីក្រុងភ្នំពេញ បើផ្អែកតាមឯកសាររបស់ក្រុមការងារពិសេសផ្នែកលំនៅដ្ឋាន (HRTF) ។ ការវាយតម្លៃចំនួនតួលេខនេះ នៅទាបនៅឡើយ ដោយថាករណីដែលកើតមាននៅក្នុងឆ្នាំ២០០០ ដល់ឆ្នាំ ២០០៣ ពុំត្រូវបានគេកត់ត្រាទុកឡើយ។

៦០- ក្នុងខែតុលា ឆ្នាំ២០០២ អនុវត្តតាមសារាចរលេខ ២ របស់ទីស្តីការគណៈរដ្ឋមន្ត្រីដែលបានអនុម័តយល់ព្រមកាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ សាលាក្រុងភ្នំពេញបានចាប់ផ្តើមរៀបចំប្លង់មេរបស់ទីក្រុងសំរាប់ឆ្នាំ២០២០។ គេបានប្រគល់ការចាត់ចែងលើកិច្ចការនេះ ទៅឱ្យការិយាល័យកិច្ចការទីក្រុង (Bureau des Affaires Urbaines) របស់សាលាក្រុងដែលមានការចូលរួមពីការិយាល័យរដ្ឋាភិបាល នាយកដ្ឋានក្រុង ខ័ណ្ឌ និងសង្កាត់។ អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ក្នុងទីក្រុងពុំបានចូលរួមក្នុងកិច្ចការនេះឡើយ។ គោលដៅរបស់ប្លង់មេនេះ គឺដើម្បីស្នើឡើងនៅក្របខ័ណ្ឌសំរាប់គម្រោងទីក្រុងដែលផ្តល់សន្ទុះថ្មី ដើម្បីអភិវឌ្ឍទីក្រុងដែលឆ្លើយតបទៅនឹងតម្រូវការនៃការរីកចំរើនក្នុងទីក្រុង។ គេមិនធ្វើការផ្សព្វផ្សាយប្លង់មេជាសាធារណៈទេ លុះត្រាតែមានការអនុម័តយល់ព្រមពីរដ្ឋាភិបាលជាមុនសិន។ ដោយមានការព្រួយបារម្ភលើកឡើងដោយអង្គការក្រៅរដ្ឋាភិបាល និងអ្នកតំណាងសហគមន៍ក្រីក្រក្នុងទីក្រុងស្តីពីកង្វះខាតនៃការចូលរួមនោះ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៥ អ្នករាយការណ៍ពិសេស ជាមួយនិងសាលាក្រុង និងអង្គការលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិ (UN-Habitat ) បានពិភាក្សាវិធី និងមធ្យោបាយ ដើម្បីធ្វើឱ្យដំណើរការដ៏មានសារសំខាន់នេះទទួលបានការពិគ្រោះយោបល់ឱ្យបានច្រើន និងដើម្បីឆ្លើយតបទៅនឹងការពិតដែលអ្នកក្រីក្រក្នុងទីក្រុងកំពុងជួបប្រទះ។ យោងតាមការស្នើឡើងរបស់អ្នករាយការណ៍ពិសេស សាលាក្រុងបានយល់ព្រម

ឱ្យមានការចូលរួមពិភាក្សាលើប្លង់មេតាមរយៈការពិគ្រោះយោបល់ជាសាធារណៈពីសង្គមស៊ីវិល និងអ្នកក្រុងក្នុងទីក្រុង។

## III. បញ្ហានៃការព្រួយបារម្ភជាពិសេស

### ក-និន្នាការចំបងៗ

៦១- យោងតាមព័ត៌មានដែលអ្នករាយការណ៍ពិសេសទទួលបាន និន្នាការខាងក្រោមនេះត្រូវបានរកឃើញៈ

- *ការបណ្តេញចេញដោយបង្ខំពីដីឯកជនៈ* ការអភិវឌ្ឍន៍ដ៏ឆាប់រហ័សរបស់ទីក្រុងភ្នំពេញអាចរំពឹងថានឹងនាំអោយមានជំលោះកើនឡើងនាពេលខាងមុខ។ ក្នុងឆ្នាំ២០០៤ របាយការណ៍របស់ក្រុមការងារពិសេស សិទ្ធិខាងលំនៅដ្ឋានបានឱ្យដឹងថា មានជំលោះចំនួន១០ កើតឡើង ដែលនាំឱ្យមាន ឬអាចឱ្យមានការបណ្តេញចេញដោយបង្ខំ។ ការដោះដូរដីបច្ចុប្បន្នបានជំរុញទៅរកនិន្នាការនេះថែមទៀត។

- *ការបណ្តេញចេញដោយបង្ខំដោយបញ្ហាពីតុលាការៈ* ការបណ្តេញចេញដោយបង្ខំដោយបញ្ហារបស់តុលាការកំពុងកើនឡើង។ និន្នាការមួយគឺថា ការបណ្តេញចេញខ្លះត្រូវបានគេធ្វើឡើងដោយរំលោភច្បាប់ដោយផ្អែកលើមូលដ្ឋាននៃការចេញដីកាកិច្ចការប្រញាប់ ដូចជាករណីកោះពេជ្រជាដើម។ និន្នាការមួយទៀត គឺការប្តូរពីករណីរឿងរដ្ឋប្បវេណីទៅជារឿងព្រហ្មទណ្ឌ។ ដើមចោទដាក់បណ្តឹងប្តឹងសហគមន៍ពីបទព្រហ្មទណ្ឌ ក្រោមច្បាប់ភូមិបាលមាត្រា២៤៧។ វិធីនេះត្រូវបានគេប្រើជាពិសេសនៅពេលដែលដីទំនាស់នោះគ្មានប័ណ្ណកម្មសិទ្ធិ។ យោលទៅតាមច្បាប់ភូមិបាល គណៈកម្មការសុរិយោដីមានយុត្តាធិការក្នុងការសំរេចថាអ្នកណាជាម្ចាស់លើអចលនទ្រព្យនោះ ក្នុងករណីដែលដីនោះគ្មានប័ណ្ណកម្មសិទ្ធិ។ ទោះជាយ៉ាងណាក៏ដោយ នីតិវិធីនេះមានការយឺតយ៉ាវ និងមិនទៀងទាត់ពីព្រោះគណៈកម្មការសុរិយោដីបច្ចុប្បន្នមិនដំណើរការ។ ការធ្វើឱ្យករណីរដ្ឋប្បវេណីក្លាយទៅជាករណីព្រហ្មទណ្ឌ ដោយដើមបណ្តឹង និងអ្នកតំណាងស្របច្បាប់ គឺដើម្បីជំរុញនីតិវិធីផ្លូវច្បាប់ឱ្យបានឆាប់រហ័ស និងដើម្បីបំភិតបំភ័យក្រុមគ្រួសារដែលងាយទទួលរងគ្រោះ។

- *ការកើនឡើងនៃការបំភិតបំភ័យ និងការគំរាមកំហែង:* និន្នាការចំបងបច្ចុប្បន្ន គឺការប្រើការគំរាមកំហែង និងការបំភិតបំភ័យពីអាជ្ញាធរមូលដ្ឋាន និងអ្នកអភិវឌ្ឍន៍ឯកជន ដែលឈានទៅរកការដោះស្រាយមួយដែលគួរឱ្យមានមន្ទិលសង្ស័យ និងឈានទៅរកការផ្លាស់ទីតាំង ឬការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្ត និងមិនមានសំណងត្រឹមត្រូវ និងយុត្តិធម៌។ ទង្វើនេះរួមមានការគំរាមកំហែងដោយប្រើកងកម្លាំងកងរាជអាវុធហត្ថ នគរបាល ការផ្តល់ព័ត៌មានមិនពិត និងពាក្យចចាមអារាមទំលាក់កំហុសដាក់លើអ្នកតំណាងរបស់អ្នកភូមិថាមានការពាក់ព័ន្ធរឿង "នយោបាយ" ឬចោទថាបានប្រព្រឹត្តបទឧក្រិដ្ឋ ក៏ដូចជាការរិតត្បិតដល់គ្រួសារដែលទទួលរងគ្រោះ ក្នុងការចេញចូលផ្ទះរបស់ពួកគេ និងការបន្ទុចបង្អាក់អ្នកភូមិមិនឱ្យមានការរួមប្រជុំជាដើម។ ក្រុមការងារពិសេសសិទ្ធិខាងលំនៅដ្ឋានបានរាយការណ៍ថា ក្នុងឆ្នាំ២០០៤ ដល់ឆ្នាំ២០០៥ នៅទីក្រុងភ្នំពេញមាន៩ ករណីដែលគេប្រើប្រាស់ការគំរាមកំហែង និងការបំភិតបំភ័យ រួមមានករណីកោះពេជ្រ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មន្ទីរពេទ្យព្រះមុន្នីវង្ស សហគមន៍បាសាក់ និងផ្លូវជាតិលេខ១។

- *ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទីក្រុង:* គម្រោងពង្រីកផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗនាំឱ្យមានការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្តនៅក្នុង និងជុំវិញភ្នំពេញនាពេលអនាគត។ យោងតាមអង្គការលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិ (UN-Habitat ) ក្នុងឆ្នាំ២០០៥-២០០៦ នៅក្នុងខ័ណ្ឌទាំង៧នៃទីក្រុងភ្នំពេញ នឹងមានគ្រួសារក្រីក្រចំនួន ៤៧៧១ គ្រួសារ (៩៣ សហគមន៍) ទទួលរងការប៉ះពាល់ដោយការពង្រីកថ្នល់ ការស្តារព្រែក បឹង និងផ្លូវរថភ្លើង។ តួលេខនេះអាចតិចជាងចំនួនពិតបើយោងទៅតាមព័ត៌មានដែលអ្នករាយការណ៍ពិសេសទទួលបាន។

- *ការរៀបចំទីក្រុងឱ្យមានសោភ័ណ្ឌភាព:* ជារៀងរាល់ឆ្នាំ ក្នុងខែវិច្ឆិកា ក្នុងអំឡុងពេលរៀបចំបុណ្យអុំទូក នគរបាលក្រុងភ្នំពេញបានប្រើប្រាស់កម្លាំង ចាប់អ្នកដែលគ្មានផ្ទះ អ្នកសុំទាន និងក្មេងស្នាក់នៅតាមចិញ្ចើមថ្នល់ បញ្ជូនពួកទាំងនេះទៅដាក់ឃុំតាមទំនើងចិត្តនៅមជ្ឈមណ្ឌលសង្គមកិច្ច ស្ថិតនៅជិតវត្តព្រៃស ។ ការ "បោសសំអាតផ្លូវ" កើតឡើងក្នុងពេលសំខាន់ៗជារៀងរាល់ឆ្នាំ។ ក្នុងខែតុលា ឆ្នាំ២០០៥ ទីស្តីការគណៈរដ្ឋមន្ត្រីបានអនុម័តអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិដើម្បីដោះស្រាយបញ្ហាអ្នកគ្មានទីជម្រកពិតប្រាកដ។ ក្រោមការដឹកនាំរបស់ក្រសួងសង្គមកិច្ច គណៈកម្មាធិការ

នេះមានសមត្ថកិច្ចក្នុងការបោសសំអាតអ្នកគ្មានទីជំរកពិតប្រាកដចំនួន ១.៨០០ នាក់ក្នុងមួយឆ្នាំៗ ពីតាមដងផ្លូវក្នុងទីក្រុងភ្នំពេញ។ អ្នកគ្មានទីជំរក អ្នកសុំទាន និងកូនក្មេងនឹងក្លាយជាគោលដៅនៃការជ្រើសរើសដោយទំនើងចិត្តលើសិទ្ធិឯកជន គ្រួសារ និងលំនៅដ្ឋាន ហើយក៏ដូចជាការដាក់ឃុំឃាំងតាមទំនើងចិត្ត ហើយនិងការរំលោភលើសេរីភាពក្នុងការដើរហើរ។

## ខ. ការិតជីវភាពក្រីក្រ

### នៅទីក្រុង

៦២- អ្នករាយការណ៍ពិសេសបានធ្វើទស្សនកិច្ចនៅសង្កាត់មួយចំនួនដែលភាគច្រើនមានចំណូលតិចតួច គឺពួកគេមិនមានទឹកស្អាត ភ្លើង និងសេវាអនាម័យផ្សេងៗ។ ពីព្រោះ ដោយសារការខ្វះខាតនូវការទទួលបានការប្រើប្រាស់សេវាសាធារណៈ ប្រជាពលរដ្ឋទាំងនោះបែរមកប្រើសេវាក្រុមហ៊ុនឯកជនជំនួសវិញ ដោយមានតម្លៃខ្ពស់បំផុត។ ការផ្តល់សេវាដោយក្រុមហ៊ុនឯកជន ពេលខ្លះមិនបានធ្វើតាមបទដ្ឋានអប្បបរមាស្តីពីសុវត្ថិភាពឡើយ។ នៅតំបន់ក្រីក្រក្នុងទីក្រុងភ្នំពេញ ការដាក់បណ្តាញភ្លើងហាក់បីដូចជាគ្មានភាពទៀងទាត់ ដោយខ្សែភ្លើងអូសបន្លាយយ៉ាងទាបតាមផ្លូវដ៏ចង្អៀត។ ល័ក្ខខ័ណ្ឌអនាម័យនៅតាមតំបន់ទាំងនោះ ជាទូទៅមានការិតទាប ចោលសំរាមគ្មានរបៀប និងបោះចោលសំរាមក្រោម និងជុំវិញផ្ទះ។ ស្ថានភាពនេះត្រូវបានរំខានដោយទឹកជំនន់ដែលកើតមានជារៀងរាល់ឆ្នាំ ដែលជាការនាំឱ្យកើតមានជំងឺឆ្លងយ៉ាងធ្ងន់ធ្ងរ។

៦៣- ចំនួនប្រជាពលរដ្ឋច្រើនលើសលុបក្នុងតំបន់ក្រីក្របណ្តាលឱ្យមានការព្រួយបារម្ភពីសុវត្ថិភាព។ ក្នុងផ្ទះដ៏តូចមួយតែងតែមានគ្រួសារលើសពីមួយគ្រួសាររស់នៅ និងនៅក្នុងសង្កាត់ខ្លះ មានចំនួនផ្ទះច្រើនលើសលុប។ វិធានការមួយដែលជាដំណោះស្រាយនោះ គឺការអភិវឌ្ឍន៍តំបន់ក្រីក្រទាំងនេះ។ ក្នុងខែឧសភា ឆ្នាំ២០០៣ លោកនាយករដ្ឋមន្ត្រីបានប្រកាសអនុញ្ញាតឱ្យមានគម្រោងអភិវឌ្ឍន៍នៅនិងកន្លែងចំនួន៤ នៅទីក្រុងភ្នំពេញៈ បូរីកីឡា ដីក្រហម រទេះភ្លើងអា (សន្តិភាព) និងរទេះភ្លើងបេ។ អ្នករាយ - ការណ៍ពិសេសបានធ្វើទស្សនកិច្ចនៅបូរីកីឡា ដែលមានប្រជាពលរដ្ឋ ១.៧៧៦ គ្រួសារនឹងទទួលបានអត្ថប្រយោជន៍ពីគម្រោងអភិវឌ្ឍន៍នេះ។ រដ្ឋាភិបាលបានអនុម័តយល់ព្រមឱ្យគម្រោងនេះទៅក្រុមហ៊ុនឯកជន

មួយ គឺក្រុមហ៊ុន ផាន អ៊ីម៉ិច ដែលបានទទួលសាងសង់អគារចំនួន១០ ដែលមានកំពស់៦ ជាន់ ឱ្យគ្រួសារទាំងនោះ ហើយជាថ្នូរនឹងការទទួលបានសិទ្ធិអភិវឌ្ឍតំបន់ពាណិជ្ជកម្មលើផ្ទៃដីប្រហែលជា ២០ ភាគរយ។ ការសាងសង់អគារចំនួន៣ បានចាប់ផ្តើមពីខែមិថុនា ឆ្នាំ២០០៤។ អ្នករាយការណ៍ពិសេសបានសាកសួរអ្នករស់នៅទីនោះ ដែលពួកគេហាក់បីដូចជាមានការពេញចិត្ត។ ប្រសិនបើធ្វើទៅមានការចូលរួមអោយបានពេញលេញ និងមានការយល់ព្រមពីប្រជាពលរដ្ឋដែលទទួលរងការប៉ះពាល់ ការចងជាដៃគូជាមួយក្រុមហ៊ុនឯកជនបែបនេះ ជាយុទ្ធសាស្ត្រមួយ ដើម្បីដោះស្រាយល័ក្ខខ័ណ្ឌរស់នៅតោកយ៉ាករបស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ក្រីក្រ។ ទោះជាយ៉ាងណាក៏ដោយ អ្នករាយការណ៍ពិសេសសូមស្នើយ៉ាងទទូចឱ្យអាជ្ញាធរតាមដានបណ្តឹងនៃគុណវិបត្តិនៃដំណើរការ ពិគ្រោះយោបល់ និងការចូលរួមមួយចំនួនក្នុងបូរីកីឡា លើសពីនេះទៅទៀត បណ្តឹងស្រដៀងគ្នានេះដែរ ពាក់ព័ន្ធនឹងគម្រោងនៃការអភិវឌ្ឍន៍នៅនឹងកន្លែងនៅដីក្រហម រទេះភ្លើងអា និងរទេះភ្លើងបេ។

៦៤- បើគម្រោងនៃការអភិវឌ្ឍន៍នៅនឹងកន្លែង ធ្វើឡើងស្របតាមនិយាមសិទ្ធិមនុស្ស វាអាចជាជំហានវិជ្ជមានទៅមុខ ក្នុងការរកដំណោះស្រាយស្ថានភាពមិនទៀងទាត់នៃប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ក្រីក្រ គេត្រូវការវិធានការកាពារជាមុន តាមរយៈការអភិវឌ្ឍន៍គោលនយោបាយលំនៅដ្ឋាននានាដើម្បីបញ្ចៀសការកើតឡើង និងការរីករាលដាលនៃតំបន់ក្រីក្រក្នុងទីក្រុង។ វាគឺជាសេចក្តីត្រូវការទាំងផែនការសកម្មភាពរយៈពេលខ្លី និងរយៈពេលវែង និងយុទ្ធសាស្ត្រពង្រីកទីក្រុងច្បាស់លាស់ ដោយរួមទាំងការផ្តល់សេវាចាំបាច់នានា ការការពារទឹកជំនន់ និងការកំណត់អត្តសញ្ញាណនៃជម្រើសខាងលំនៅដ្ឋាន ដែលមិនត្រឹមតែអាចធ្វើឱ្យអ្នកតាំងទីលំនៅថ្មីមានជីវភាពរស់នៅមានចិរភាពប៉ុណ្ណោះទេ តែវាអាចបង្កើតឱ្យមានលំនៅដ្ឋានសមរម្យសំរាប់អ្នករស់នៅក្នុងតំបន់ក្រីក្រផងដែរ។

**តំបន់ជនបទ**

៦៥- កង្វះខាតស្ទើតែទាំងស្រុងនៃសេវាសាធារណៈ គឺជាការព្រួយបារម្ភដ៏ធំមួយនៅតំបន់ជនបទ។ នៅអំឡុងពេលបំពេញបេសកកម្មរបស់អ្នករាយការណ៍ពិសេស ដីនៅជាប់សងខាងទន្លេទទួលរងទឹកជំនន់ តំបន់ដែលនៅឆ្ងាយពីទន្លេទទួលរងគ្រោះពីផលវិបាកដោយការមានភ្លៀងធ្លាក់តិចតួច។ ដោយសារភាពរាំងស្ងួតដែលមានរយៈពេលយូរនោះ គ្រួសារនៅតំបន់ជនបទមិនអាចប្រកបរបរកសិកម្មបានឡើយ

សូម្បីតែស្រែក៏មិនផ្តល់ផលដែរ ដែលធ្វើឱ្យស្ថានភាពក្រីក្រកាន់តែដុនដាបឡើងនៅក្នុងតំបន់ ទាំងនោះ។ ស្ថានភាពបែបនេះ មិនមែនជារឿងថ្មីនោះទេ តែវាបានធ្វើឱ្យគ្រួសារជាច្រើនបញ្ជូនកូនរបស់ ពួកគេ ជាពិសេសក្មេងស្រី និងនារីវ័យជំទង់ទៅកាន់ទីក្រុង ដើម្បីរកការងារធ្វើ ជាអាទិ៍ធ្វើការក្នុងរោងចក្រ កាត់ដេរជាដើម។

៦៦- ក្រុមគ្រួសារប្រជាពលរដ្ឋនៅជនបទបានរាយការណ៍ឱ្យដឹងផងដែរ អំពីការកើនឡើងនៃការជួញដូរដី។ ផ្អែកលើសាក្សីកម្មដែលអ្នករាយការណ៍ពិសេសទទួលបាននោះថា ដោយប្រទេសកម្ពុជាកំពុងមានស្ថិរភាព អ្នកមកពីក្រៅកំពុងទិញដីដែលពុំមានតម្លៃទាំងនោះទុកចោល ដោយតម្លៃយ៉ាងថោក។ អ្នកធ្វើគំរោងទីក្រុងខ្លះ បានអះអាងថាកន្លែងទាំងនេះនឹងមានអត្ថប្រយោជន៍នាពេលអនាគតខាងមុខ ដោយនឹងទទួលផលពីគម្រោងអភិវឌ្ឍន៍របស់រដ្ឋាភិបាលដែលនឹងនាំឱ្យដីទាំងនោះឡើងថ្លៃ។ គេបានរាយការណ៍ថា ដោយសារភាពរាំងស្ងួត គ្រួសារជាច្រើនបានបង្ខំចិត្តលក់ដីរបស់ពួកគេ ដើម្បីបានប្រាក់ទិញអាហារនិងរបស់របរចាំបាច់ផ្សេងទៀត។ ទាំងនេះគឺជារឿងធម្មតាទៅហើយនៅតាមតំបន់ជនបទនៃប្រទេសកម្ពុជាដែលគ្រួសារនានាតែងតែមានដីពីរកន្លែង មួយកន្លែងជាដីភូមិ ឯមួយកន្លែងទៀតជាដីសំរាប់ធ្វើស្រែ។ នៅពេលដែលគ្រួសារទាំងនោះលក់ដីក្នុងកាលៈទេសៈដូចពណ៌នាខាងលើ គឺគេលក់ដីស្រែរបស់ពួកគេ។ ដូច្នេះហើយភាគច្រើនការលក់ដូរដីទាំងនោះ មិនធ្វើឱ្យពួកគេអត់ជម្រកឡើយ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលខាងមុខ ការលក់ដីកសិកម្មទាំងនោះនឹងធ្វើឱ្យប៉ះពាល់ជាពិសេសដល់ជីវភាពរស់នៅរបស់គ្រួសារទាំងនោះ និងធ្វើឱ្យគ្រួសារទាំងនោះចាកចេញពីតំបន់ជនបទទៀតផង។

## គ- ជនជាតិដើមភាគតិច

៦៧- អ្នករាយការណ៍ពិសេសបានជួបជាមួយតំណាងជនជាតិដើមផ្សេងៗគ្នារបស់ជនជាតិដើមភាគតិចមាន (ចារ៉ាយ ភ្នង សួយ គួយ ទំពួន គ្រឹង) ដែលមកពីខេត្តផ្សេងៗគ្នា។ ដោយផ្អែកលើការរកឃើញរបស់លោកអ្នករាយការណ៍ពិសេសសូមលើកឡើងថា សម្បទានដី[៦] ការកាប់ឈើ ការធ្វើរ៉ែ ហើយនិងគំរោងនៃការអភិវឌ្ឍន៍ធំៗដទៃទៀត[៧] នៅតំបន់ដែលកាន់កាប់ដោយជនជាតិដើមកម្ពុជាភាគតិចនោះ នាពេលអនាគតនឹងបណ្តាលឱ្យបាត់បង់សហគមន៍ពីបូរាណរបស់ពួកគេ។ ក្រៅពីការបាត់បង់ជម្រក នៅពេលប៉ះពាល់ដល់កន្លែង

រស់នៅនោះ គម្រោងទាំងនេះវាជះឥទ្ធិពលផងដែរដល់ជីវភាពរបស់ក្រុមជនជាតិ។ គេបានព័ទ្ធរបងបិតតាមកន្លែងជាច្រើនដែលមិនអាចឱ្យអ្នកក្រៅចូលបាន ហើយដែលកន្លែងទាំងនោះ កាលពីដើមប្រើប្រាស់ដោយសហគមន៍ជនជាតិដើមភាគតិច ក្នុងការប្រមូលអនុផលព្រៃឈើ និងការរក្សាដីទាំងនោះសំរាប់ប្រព័ន្ធកសិកម្មពន្ទេចរជាប្រពៃណីរបស់ពួកគេ។ ដោយហេតុថា សិទ្ធិមានលំនៅដ្ឋានសមរម្យពាក់ព័ន្ធគ្នាជាមួយសិទ្ធិខាងសុខភាព សិទ្ធិខាងចំណីអាហារ និងសិទ្ធិទទួលបានសុវត្ថិភាពខាងបរិស្ថាន ហើយនិងជាងនេះទៅទៀត សិទ្ធិមានលំដ្ឋានសមរម្យរបស់ជនជាតិដើមភាគតិច ដែលជាផ្នែកមួយនៃសិទ្ធិទទួលបានក៏រិតជីវភាពសមរម្យ អាចទទួលរងការប៉ះពាល់ដោយសកម្មភាពទាំងនោះ អ្នករាយការណ៍ពិសេសនឹងលើកឡើងដូចខាងក្រោមនេះបន្ថែមទៀត។

៦៨- ជាងនេះទៅទៀត ការលក់ដូរដីជាឯកជនដោយខុសច្បាប់កំពុងកើនឡើង។ យោងតាមច្បាប់ភូមិបាលតាំងតែពីមុនការទទួលស្គាល់ និងការកំណត់ព្រំដែនដីរបស់ពួកគេនោះ ក្រុមជនជាតិដើមភាគតិច ត្រូវគ្រប់គ្រងអចលនព្រទ្យទៅតាមប្រពៃណីពីបុរាណរបស់គេ។ ដូចបានពិភាក្សាខាងលើ (អនុផ្នែក ១. គ) ច្បាប់ភូមិបាលបានផ្តល់កម្មសិទ្ធិជាសមូហភាពលើដីជាប្រពៃណីដែលកាន់កាប់ដោយក្រុមជនជាតិភាគតិច សំរាប់ទាំងគោលបំណងធ្វើជាជម្រក និងទាំងគោលបំណងធ្វើកសិកម្ម។

៦៩- ទោះជាយ៉ាងណា ដើម្បីអនុវត្តបញ្ញត្តិស្តីពីកម្មសិទ្ធិសមូហភាពនៃច្បាប់ភូមិបាលឱ្យមានប្រសិទ្ធិភាពនោះ គឺវាតម្រូវឱ្យមានការអនុម័តអនុក្រឹត្យ ដើម្បីសំរបសំរួលបាននោះ គឺត្រូវរង់ចាំការអនុម័តច្បាប់ដែលចែងអំពីជនជាតិដើម/ជនជាតិភាគតិចក្នុងប្រទេសកម្ពុជាសិន ដែលច្បាប់នេះកំពុងតែព្រៀងដោយក្រសួងមហាផ្ទៃ។ ការផ្ទេរដីដោយខុសច្បាប់បានធ្វើឱ្យយឺតយ៉ាវដល់ការអនុម័តនេះ។ ជាឧទាហរណ៍ ការលក់ដីជាឯកជនកំពុងតែធ្វើឱ្យសហគមន៍ជនជាតិភាគតិចបាត់បង់សិទ្ធិភោគៈជាសមូហភាពរបស់ខ្លួន។ គេបានរាយការណ៍ថា មានករណីលក់ដីជនជាតិដើមភាគតិចជាច្រើន ដែលធ្វើឡើងដោយសមាជិកជនជាតិដើមភាគតិច ឬដោយមេឃុំ ដោយមិនបានធ្វើការពិគ្រោះ យោបល់ជាមួយសហគមន៍របស់ខ្លួនជាមុន។ ការនេះបានធ្វើឱ្យអ្នករាយការណ៍ពិសេសចាប់អារម្មណ៍លើការផ្តល់កំរៃមិនផ្លូវការទៅលើការចេញលិខិតកាន់កាប់ក្លែងបន្លំ។ អ្នករាយការណ៍ពិសេសសូមធ្វើការគូសបញ្ជាក់ថា ការផ្ទេរសិទ្ធិកាន់កាប់ជាសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលធ្វើឡើងដោយសមាជិកណាម្នាក់នៃសហគមន៍ជនជាតិដើមភាគតិចឱ្យទៅជាការកាន់កាប់ជាឯកជននោះ គឺអាចប្រព្រឹត្ត

ទៅបានតែនៅក្រោយការអនុម័តអនុក្រឹត្យដូចបានរៀបរាប់ខាងលើប៉ុណ្ណោះ។ នៅក្នុងអំឡុងពេលសរសេររបាយការណ៍នេះ ពុំមានការបង្កើតនីតិវិធីដើម្បីអនុញ្ញាតការផ្ទេរសិទ្ធិរបៀបនេះឡើយ។ ដូច្នេះហើយ ការលក់ដូរដីរបស់ជនជាតិដើមភាគតិចជាឯកជនពីសមាជិកជនជាតិដើមភាគតិចណាម្នាក់នោះ គឺខុសច្បាប់។

៧០- មានដីជាច្រើនដែលគេយកពីជនជាតិដើមភាគតិចក្នុងគោលបំណងធ្វើសកម្មភាពកាប់ឈើ ដែលនាំឱ្យមានការគំរាមកំហែងដល់ការតាំងទីលំនៅ និងស្ថិរភាពនៃបរិស្ថានដែលជាកន្លែងសហគមន៍ទាំងនោះរស់នៅតាំងពីដូនតាមក។ ការរីករាលដាលកាន់តែធំឡើងនៃសកម្មភាពទាំងនេះ ធ្វើឱ្យគ្រោះថ្នាក់ដល់បរិស្ថាននៅកន្លែងដែលជនជាតិដើមភាតិចរស់នៅ គឺជាផលវិបាកនាំឱ្យមានការកើនឡើងនៃសម្បទានដីសេដ្ឋកិច្ច និងគម្រោងអភិវឌ្ឍន៍ធំៗនានា។ គម្រោងអភិវឌ្ឍន៍ទាំងនោះចរចាធ្វើឡើងដោយរដ្ឋាភិបាល ដោយគ្មានការចូលរួមពីសហគមន៍ជនជាតិដើមភាគតិចឡើយ ដូច្នេះហើយ សម្បទានដីនោះនឹងធ្វើទៅលើដីដែលគេយល់ថា ជាដីបុព្វបុរសរបស់ពួកគេ។ ដោយយោលទៅតាមសាក្ខីកម្ម និងការធ្វើទស្សនកិច្ចរបស់លោកនៅកន្លែងនោះ អ្នករាយការណ៍ពិសេសយល់ថា សហគមន៍ជនជាតិដើមភាគតិចត្រូវបានគេដកហូតជីវភាពដែលមានស្ថិរភាពជាប្រពៃណីរបស់ពួកគេ ដោយកើតចេញពីការធ្វើសកម្មភាពកាប់ឈើ សម្បទានដីឱ្យទាហាន និងគម្រោងដើម្បីទាក់ទាញទេសចរណ៍ បានធ្វើឱ្យពួកគេចាកចោលផ្ទះពីបុរាណដោយបង្ខំ ហើយទៅរស់នៅកន្លែងផ្សេងទៀតមានចំនួនកាន់តែកើនឡើង។

៧១- កិច្ចប្រតិបត្តិការនេះច្រើនធ្វើឡើងដោយគ្មានការជូនដំណឹងឱ្យសហគមន៍ជនជាតិដើមភាគតិចចូលរួមឡើយ ហើយធ្វើដោយមានការបំភិតបំភ័យ ការគំរាមកំហែង ហើយជាលទ្ធផលគឺមិនបានធ្វើតាមកិច្ចសន្យាដែលធ្វើឱ្យបាត់បង់ជម្រក និងនាំឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាន និងកេរ្តិ៍ដំណែលជាប្រពៃណីរបស់ពួកគេ។ ការទទួលបានសិទ្ធិការពារដោយស្មើភាពគ្នាតាមផ្លូវច្បាប់ និងសុវត្ថិភាពបុគ្គលរបស់សហគមន៍ជនជាតិដើមភាគតិចទាំងនេះ ត្រូវបានគេធ្វើឱ្យអន្តរាយ។ ពួកគេត្រូវបានគេរឹតត្បិតផងដែរ លើសេរីភាពនៃការបង្កើតសមាគម សេរីភាពក្នុងការរួមប្រជុំ សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការដើរហើរ។

## ឃ-ស្ត្រី

៧២- ក្នុងពេលបំពេញបេសកកម្ម គេបានរៀបចំការពិគ្រោះយោបល់ក្នុងវេទិកាតុមូលជាមួយនឹងស្ត្រី ដែលមកពីសង្កាត់នានាក្នុងទីក្រុងភ្នំពេញ ដើម្បីធ្វើការពិភាក្សាពីឧបសគ្គចំបងៗ ដែលស្ត្រីជួបប្រទះក្នុងការប្រឹងប្រែង

ដើម្បីធានាដល់លក្ខខ័ណ្ឌនៃសុវត្ថិភាពលំនៅដ្ឋានសមរម្យរបស់គេ និងក្រុមគ្រួសារ។ សាក្ខីកម្មទទួលបានពីការពិភាក្សាតុមូល ទិន្នន័យដែលបានផ្តល់ និងការធ្វើសំភាសន៍នាពេលធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ និងតាមខេត្ត ដោយរួមទាំងស្ត្រីជនជាតិដើមភាគតិចផង បានបញ្ចូលក្នុងរបាយការណ៍នេះ។ សាក្ខីកម្មទាំងនោះ គឺផ្តោតទៅលើតែផលវិបាកនៃការបណ្តេញចេញដោយបង្ខំ និងកម្មវិធីនៃការតាំងទីលំនៅថ្មីដែលកើតឡើងចំពោះស្ត្រី។

៧៣- នៅពេលដែលសហគមន៍ទទួលរងការគំរាមកំហែងពីការបណ្តេញចេញ ជានិច្ចជាកាលស្ត្រីតែងតែជាអ្នកប្រឈមនឹងស្ថានការណ៍ ដែលនៅក្នុងករណីជាច្រើនមានការពាក់ព័ន្ធទៅនឹងការគំរាមកំហែង និងអំពើហឹង្សា។ នៅកន្លែងដែលគេរើទៅតាំងទីលំនៅថ្មី ភាគច្រើនមានការខ្វះខាតខាងលក្ខខ័ណ្ឌអនាម័យ ដែលជាពិសេសនាំឱ្យមានការលំបាកដល់ស្ត្រី ដែលពួកគេស្ទាក់ស្ទើក្នុងការធ្វើអនាម័យផ្ទាល់ខ្លួននៅកណ្តាលវាលនោះ។ មានស្ត្រីជាច្រើនដែលរស់នៅក្នុងតំបន់ក្រីក្រ រកទទួលទានជាសកម្មភាពជំនួញផ្សេងៗ ឬធ្វើការជាធម្មតា ដើម្បីទទួលកំរៃបន្ថែមសំរាប់ផ្សែផ្សំបន្ថែមលើចំណូលគ្រួសារ។ ដោយហេតុថា ការតាំងទីលំនៅថ្មីមានចម្ងាយឆ្ងាយពីទីក្រុងនោះ សកម្មភាពរកទទួលទានទាំងនោះត្រូវបាត់បង់ដោយសារការធ្វើដំណើរទៅមកមានតំលៃខ្ពស់ពេក។

៧៤- របាយការណ៍របស់ស្ត្រីទាំងនោះបានឆ្លុះបញ្ចាំងឱ្យឃើញផងដែរនូវការលំបាកនានា ដែលកើតចេញពីទស្សនៈនៃវប្បធម៌ពាក់ព័ន្ធនឹងតួនាទីរបស់ស្ត្រីនៅក្នុងសង្គមកម្ពុជា។ យោលទៅតាមពួកគេ គេបានឱ្យដឹងថាស្ត្រីជាធម្មតាជួបប្រទះនូវការរើសអើង នៅពេលធ្វើការចរចាទាមទារសំណង ការតាំងទីលំនៅថ្មី និងការទទួលបានសេវាកម្មចាំបាច់នានាជាមួយអាជ្ញាធរ និងក្រុមហ៊ុន។ សំរាប់គ្រួសារដែលមានស្ត្រីជាមេផ្ទះនោះ ស្ថានការណ៍កាន់តែយ៉ាប់យឺនទៅទៀត ដោយមានរបាយការណ៍ថា នៅពេលដែលពុំមានបុរសនៅជាមួយ ស្ត្រីទាំងនោះទទួលបានសំណងតិចជាងគេនៅក្នុងករណីបណ្តេញចេញ និងទទួលបានដីតូចជាងគេនៅឯកន្លែងដែលត្រូវតាំងទីលំនៅថ្មី។

៧៥- អស្ថិរភាពដែលកើតចេញពីលក្ខខ័ណ្ឌរស់នៅមិនគ្រប់គ្រាន់យ៉ាងធ្ងន់ធ្ងរនោះ បានធ្វើឱ្យប៉ះពាល់ដល់ការងារប្រចាំថ្ងៃរបស់ស្ត្រី។ ដោយជាប់ពាក់ព័ន្ធជាមួយលក្ខខ័ណ្ឌមិនទៀងទាត់នៃតំបន់ក្រីក្រ ស្ត្រីតែងតែភ័យព្រួយពីភ្លើងឆេះ ឬទឹកជំនន់ ឬព្រួយបារម្ភពីសុខមាលភាពកូនៗរបស់ពួកគេ។ គេបានបំភ្លឺថា មានផ្លូវតិចតួចណាស់ក្នុងការចរចាជាមួយអាជ្ញាធរពាក់ព័ន្ធ សុំឱ្យមានការប្រឹងប្រែងដើម្បីអាចអភិវឌ្ឍនៅនឹងកន្លែងបាន។ ពួក

គាត់មានប្រសាសន៍ដដែលៗថា ពួកគាត់ជាអ្នកតាំងទីលំនៅដោយខុសច្បាប់ ហើយដោយហេតុនេះ គឺពុំមានការអភិវឌ្ឍន៍ធ្វើឱ្យកន្លែងដែលពួកគាត់រស់នៅបានប្រសើរឡើងឡើយ ។

៧៦- ការព្រួយបារម្ភធំៗផ្សេងទៀត គឺស្ថានភាពជនរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ ។ ដោយការជាប់ពាក់ព័ន្ធជាមួយនឹងការរារាំងផ្នែកសេដ្ឋកិច្ច និងផ្នែកវប្បធម៌ ស្ត្រីដែលធ្លាប់ទទួលការរំលោភមានលទ្ធភាពនៅមានកំរិតក្នុងការចាកចេញពីផ្ទះ ដើម្បីទទួលបានលំនៅដ្ឋានសមរម្យនៅកន្លែងផ្សេងទៀត ។ ថ្មីៗនេះ រដ្ឋសភាបានអនុម័តច្បាប់ថ្មីមួយ គឺច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ ។ បើតាមច្បាប់ថ្មីនេះ ស្ត្រីដែលត្រូវគេរំលោភអាចទទួលបានការការពារដែលចេញដោយតុលាការ ដើម្បីហាមឃាត់បុរសមិនឱ្យចូល ឬសូម្បីតែទៅក្បែរផ្ទះដែលគាត់ធ្លាប់រស់នៅជាមួយជនរងគ្រោះក្តី ។ ស្ត្រីដែលរងអំពើហឹង្សាបានទទួលរងទុក្ខសោកផងដែរពីការដែលរដ្ឋពុំមានជំរកគ្រប់គ្រាន់សំរាប់ឱ្យជនរងគ្រោះស្នាក់នៅ ។

៧៧- ស្ត្រីទាំងនោះបានលើកឡើងផងដែរអំពីការព្រួយបារម្ភ ដែលបណ្តាលមកពីការរិតត្បិតក្នុងការទទួលបានសិទ្ធិជាម្ចាស់លើផ្ទះ និងដីធ្លី ។ ច្បាប់អាពាហ៍ពិពាហ៍របស់ប្រទេសកម្ពុជា បានផ្តល់សិទ្ធិស្មើភាពគ្នាដល់សហព័ទ្ធក្នុងការធ្វើជាម្ចាស់ទ្រព្យ ។ ទ្រព្យសម្បត្តិដែលរកបាននៅពេលដែលមានចំណងអាពាហ៍ពិពាហ៍ គឺជាទ្រព្យរួមរវាងសហព័ទ្ធទាំងពីរ ហើយបើមានការលែងលះទ្រព្យទាំងនោះត្រូវចែកជាចំណែកស្មើគ្នា ។ ទោះជាយ៉ាងណាក៏ដោយ ជាក់ស្តែង ជាធម្មតាគេដាក់តែឈ្មោះប្តីប៉ុណ្ណោះនៅក្នុងប័ណ្ណកម្មសិទ្ធិ ។

៧៨- ច្បាប់ភូមិបាលឆ្នាំ២០០១ និងបទបញ្ញត្តិថ្មីស្តីពីសុរិយោដី ហាក់បីដូចជាជួយលើកទឹកចិត្តធ្វើឱ្យមានការផ្លាស់ប្តូរលើប្រការនេះ ។ ក្នុងការធ្វើអង្កេតឆ្នាំ២០០៣ (គម្រោងគ្រប់គ្រងរដ្ឋបាលដីធ្លី របស់ធនាគារពិភពលោក) បង្ហាញថា ក្នុងឆ្នាំ២០០១ គេបានផ្តល់ប័ណ្ណកម្មសិទ្ធិចំនួន ៨0.000 ប័ណ្ណ ហើយក្នុងនោះមានប្រមាណ ៧៨ ភាគរយដែលគេបានដាក់ឈ្មោះប្តី និងប្រពន្ធថាជាម្ចាស់ទ្រព្យ ។ តែទោះជាយ៉ាងណាក៏ដោយ ការសិក្សាដូចគ្នានេះ បានបង្ហាញឱ្យឃើញជាពិសេសថា "បើស្ត្រីជាមេផ្ទះ គឺងាយទទួលរងនូវការដែលគេមិនអើពើចំពោះសិទ្ធិរបស់ពួកគេ ដោយហេតុមកពីកង្វះខាតចំណេះដឹងអំពីសិទ្ធិលើដីធ្លី និងចំណេះដឹងអំពីនីតិវិធីធ្វើប័ណ្ណកម្មសិទ្ធិ" [៨] ។

៧៩- ទិន្នន័យនេះគឺវាពិបាកនឹងសំរេចថា គ្រួសារដែលមានស្ត្រីជាមេផ្ទះនោះគឺជាគ្រួសារក្របំផុតនៅក្នុងសហគមន៍ ហើយបើនៅតាមជនបទ ស្ត្រីមេម៉ាយដែលមានកូននៅក្មេងៗ ដែលពុំមានអ្នកធ្វើការជាមនុស្សចាស់នោះ គឺជាក្រុមដែលងាយធ្លាក់ចូលទៅរកភាពក្រីក្រ នេះបើតាមការធ្វើអង្កេតរបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០០១[៩] ។ របាយការណ៍ជំរឿនប្រជាពលរដ្ឋថ្នាក់ជាតិឆ្នាំ១៩៩៨ បានឱ្យដឹងថា នៅប្រទេសកម្ពុជាមានស្ត្រីជាមេគ្រួសារ២៥.៧ ភាគរយ ហើយទិន្នន័យដែលចែកឱ្យដាច់ចំពោះតំបន់ជនបទមានអត្រាខ្ពស់ជាងបន្តិច គឺមាន២៧.២ ភាគរយ[១០] ។

## IV. កំណត់សំគាល់សន្និដ្ឋាន និងអនុសាសន៍ផ្សេងៗ

៨០- នៅកម្ពុជាកត្តាប្រវត្តិសាស្ត្រជួយពន្យល់អំពីការលំបាក ដែលប្រទេសនេះបានជួបប្រទះនាពេលបច្ចុប្បន្ននេះ រួមទាំងភាពផុយស្រួយនៃក្របខ័ណ្ឌស្ថាប័នផ្លូវច្បាប់ដែលកំពុងមានសព្វថ្ងៃ ដែលជាប់ពាក់ព័ន្ធរវាងការទទួលបានលំនៅដ្ឋានសមរម្យ និងការទទួលបានដីធ្លី ។

៨១- គេត្រូវលើកយកមកដោះស្រាយជាចំបងនូវបញ្ហាបទបញ្ញត្តិមិនច្បាស់លាស់ មិនគ្រប់គ្រាន់ ហើយនិងការដែលអាជ្ញាធរអនុវត្តច្បាប់មិនទាន់បានល្អ ដោយបង្កើតឡើងនូវការអភិវឌ្ឍន៍នៃគោលនយោបាយបែបថ្មី ដើម្បីដោះស្រាយឱនភាពផ្នែកលំនៅដ្ឋាន និងផលវិបាកដ៏ធ្ងន់ធ្ងរនៃភាពក្រីក្រ និងការគ្មានដីធ្លីក្នុងប្រទេសនេះ ដែលបញ្ហាទាំងនេះ គឺស្ថិតក្រោមសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ ។

៨២- ដូច្នេះហើយ អ្នករាយការណ៍ពិសេស ទទូចយ៉ាងខ្លាំងចំពោះការអនុម័តយល់ព្រមយកគោលដៅអវិភាគមួយដោយគោរពដល់សិទ្ធិមានលំនៅដ្ឋានសមរម្យ ហើយនិងសិទ្ធិដទៃទៀតដែលមានការទាក់ទងដល់អាណត្តិរបស់លោក ហើយលោកសូមដាក់ជូននៅអនុសាន៍ជាក់លាក់មួយចំនួនដូចខាងក្រោមនេះ :

(ក) មានតម្រូវការជាបន្ទាន់ក្នុងការគូសផែនទីច្បាស់លាស់មួយសំរាប់សេចក្តីត្រូវការខាងលំនៅដ្ឋានរបស់ប្រទេសនេះ ហើយធ្វើការបកស្រាយទិន្នន័យចេញពីទស្សនៈនៃសិទ្ធិមនុស្ស ក្នុងគោលបំណងធ្វើការអភិវឌ្ឍន៍គោលនយោបាយលំនៅដ្ឋានជាតិទូលំទូលាយមួយ ។

(ខ) ដោយផ្សាភ្ជាប់ទៅនឹងអនុសាសន៍លើកមុន គឺមានសេចក្តីត្រូវការក្នុងការបង្កើនឱ្យមានតម្លាភាពនៅក្នុងការអភិវឌ្ឍន៍គោលនយោបាយ និងការបើកចំហរដល់ការវាយតម្លៃជាអាទិភាព លទ្ធផល និងការផ្តល់សេរីភាពដល់ការឃ្លាំមើលជាសាធារណៈ និងការចូលរួមយ៉ាងពេញលេញពីប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ។

(គ) គេត្រូវយកចិត្តទុកដាក់មុនគេបង្អស់ដល់គ្រួសារដែលរស់នៅក្នុងគេហដ្ឋានដែលទ្រុឌទ្រោម និងស្ថានភាពរស់នៅតោកយ៉ាកខ្លាំង រួមមានអ្នករស់នៅក្នុងតំបន់ក្រីក្រ និងតំបន់តាំងទីលំនៅថ្មី ជាមួយនិងការផ្តល់ជាបន្ទាន់នូវសេវាមូលដ្ឋានសំរាប់ការរស់នៅ ។

(ឃ) គេត្រូវតែអនុវត្តជាបន្ទាន់នូវបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងលំនៅដ្ឋានរបស់ច្បាប់ភូមិបាលឆ្នាំ ២០០១ រួមទាំងអនុក្រឹត្យដែលបានអនុម័តនាពេលថ្មីៗនេះ ។ គេត្រូវអនុម័តច្បាប់ដែលរួមមានបទបញ្ញត្តិស្តីពីស្ថានភាពលំនៅដ្ឋាននៃគ្រួសារដែលរស់នៅលើដីសាធារណៈរបស់រដ្ឋ និងបំភ្លឺពីស្ថានភាពផ្លូវច្បាប់ដែលពាក់ព័ន្ធដល់ការដោះដូរដីទាំងអស់ដែលកើតឡើងក្នុងរង្វង់ច្បាប់ភូមិបាល និងក្នុងពេលច្បាប់នេះអនុម័ត ។ ជាងនេះទៅទៀត ព័ត៌មានដែលទាក់ទងទៅនឹងការដោះដូរដីដែលកំពុងធ្វើការចរចា ត្រូវបញ្ចេញឱ្យគេដឹងជាសាធារណៈឱ្យបានឆាប់ ។ ជាមួយគ្នានេះដែរ ក្រៅពីការដោះដូរដីដែលធ្វើរួចហើយ គេត្រូវយកចិត្តទុកដាក់លើគ្រួសារដែលបានទទួលរងការប៉ះពាល់ដោយធានាឱ្យពួកគេមានស្ថានភាពលំនៅដ្ឋានសមរម្យ ហើយនិងធានាឱ្យមានស្ថិរភាពក្នុងការកាន់កាប់ដីរបស់ខ្លួននៅកន្លែងតាំងទីលំនៅថ្មី ។ នៅពេលដែលការបណ្តេញចេញត្រូវបានផ្អាក គេត្រូវប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដោយគិតថាការតាំងទីលំនៅថ្មី គឺជាមធ្យោបាយចុងក្រោយបំផុត និងធានាឱ្យមានការចូលរួមពីសហគមន៍ដែលទទួលរងផលប៉ះពាល់ ។

(ង) ត្រូវអនុម័តច្បាប់ជាតិស្តីពីការបណ្តេញចេញ ដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសយោបល់រួមទី៤ និងទី៧ របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

(ច) តុលាការ និងគណៈកម្មការសុរិយោដីមានតួនាទីយ៉ាងសំខាន់ក្នុងជម្លោះលំនៅដ្ឋាន ហើយគេត្រូវតែពង្រឹងកិច្ចការរបស់ពួកគេ តាមរយៈការគោរពធម្មាធិបតេយ្យឱ្យបានហ្មត់ចត់ និងនីតិវិធីត្រឹមត្រូវ ដោយរួម

ទាំងការបង្កើតឱ្យមាននីតិវិធីអង្កេតមួយដែលមិនលំអៀងក្នុងការពិនិត្យយថាភូតនៃប័ណ្ណកម្មសិទ្ធិរបស់បណ្ដឹង និងពិនិត្យឡើងវិញរាល់សេចក្ដីសំរេចរបស់តុលាការនិងសេចក្ដីសំរេចរដ្ឋបាល ។

(ឆ) គេត្រូវបង្កើតឡើងនូវគោលនយោបាយជាក់លាក់មួយ ដើម្បីដោះស្រាយបញ្ហារើសអើងលើស្ត្រីពាក់ព័ន្ធទៅនឹងការទទួលបានដោយស្មើភាពនូវសិទ្ធិកាន់កាប់លើលំនៅដ្ឋាន និងដីធ្លី ។ គោលនយោបាយបែបនោះ ត្រូវផ្ដល់ដំណោះស្រាយនូវផលប៉ះពាល់ជាអវិជ្ជមាន និងវិសមមាត្រ ដែលកើតចេញពីការបណ្ដេញចេញដោយបង្ខំ ការអត់ទីជំរក និងលក្ខខ័ណ្ឌរស់នៅក្រីក្រកើតមានចំពោះស្ត្រី ។

(ជ) វិធានការនានា ដើម្បីធ្វើឱ្យជនជាតិដើមភាគតិចទទួលបាននូវសិទ្ធិលំនៅដ្ឋានសមរម្យនោះ គេត្រូវបញ្ចូលការគោរពដល់ដីធ្លីពីបូរាណរបស់គេ និងធ្វើឱ្យបានល្អិតល្អន់នូវគោលនយោបាយដីធ្លី និងលំនៅដ្ឋានដែលមានវេទយិតភាពខាងវប្បធម៌ ។ រហូតដល់ការអនុម័តអនុក្រឹត្យស្ដីពីកម្មសិទ្ធិសមូហភាពលើដីជនជាតិដើមភាគតិច អាជ្ញាធរពាក់ព័ន្ធគួរគិតគូឱ្យមានការផ្អាកជាបណ្ដោះអាសន្ននូវការលក់ដីដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច ។

(ឈ) គេត្រូវអនុម័តវិធានការ ដើម្បីសំរបសំរួលដល់កិច្ចការខាងសិទ្ធិមនុស្ស និងកិច្ចការអភិវឌ្ឍន៍របស់អង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសនេះ និងគោរពឱ្យបានពេញលេញដល់សេរីភាពក្នុងការបង្កើតសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពក្នុងការដើរហើរ ។

៨៣- ឧបសគ្គដែលកំពុងកើតមានដល់ការអនុវត្តន៍សិទ្ធិមានលំនៅដ្ឋានសមរម្យជាផ្នែកមួយដ៏ធំ ហើយទាមទាឱ្យមានការខិតខំរួមគ្នាមិនត្រឹមតែពីសំណាក់រដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែពីសំណាក់អង្គការក្រៅរដ្ឋាភិបាលថ្នាក់ជាតិ ព្រមទាំងសហគមន៍អន្តរជាតិផងដែរ ។

<u>កំណត់សំគាល់</u>

[១] សូមអាន ជាពិសេសរបាយការណ៍ **E/CN.4/2005/116,** កថាខ័ណ្ឌ ៤២-៦០ និងរបាយការណ៍ **E/CN.4/2006/110** ។

[២] របាយការណ៍ស្រប ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់គណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលក្នុងការឃ្លាំមើលការអនុវត្តន៍សិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចុះខែសីហា ឆ្នាំ២០០៦ ទំព័រ ២៥-២៦ ។

[៣] ឯកសារ ការស្ទង់ប្រជាសាស្ត្រលើកទី១របស់កម្ពុជា ឆ្នាំ១៩៩៨-២០២០ ខែមិថុនា ឆ្នាំ២០០៤ ទំព័រទី ២៨។ ការធ្វើជំរឿនឆ្នាំ២០០៤ ដោយវិទ្យាស្ថានស្ថិតិជាតិមានកំហុសយ៉ាងធ្ងន់ធ្ងរ ។ ស្ថិតិប្រជាពលរដ្ឋក្នុងទីក្រុងភ្នំពេញ ឆ្នាំ២០០៤ មាន ១,០៤៣,៦៦៩ ដែលការស្ទង់មើលដោយស្ថាប័នតែមួយនេះ បានប៉ាន់ប្រមាណថាមាន ១,២៧២,៣៨៦ ក្នុងឆ្នាំដូចគ្នានេះ ។ ការធ្វើអង្កេតលើកទីមួយ មិនបានគិតដល់ចំនួនកម្មការនីដែលមកធ្វើការនៅតាមរោងចក្រនានា មានចំនួនដល់ ១៥០,០០០ ក្នុងឆ្នាំ១៩៩៨ ឡើយ (**/in Phnom Penh/ Urbanisme, lettre d’information, juin 2005**) ។

[៤] សូមអានឯកសារដែលមានចំណងជើង ***Evolution des formesurbaines de Phnom Penh, Cambodge Nouveau.*** ទំព័រទី១៣ របស់លោក អេរិចហ៊ុយប្រិក ចុះខែឧសភា ឆ្នាំ២០០៥ ។

[៥] សូមអានឯកសាររបស់ក្រសួងការបរទេស និងសហប្រតិ្តការអន្តរជាតិ និងស្ថានទូតបារាំងប្រចាំនៅកម្ពុជា មានចំណងជើង ***Le marché immobilierde Phnom Penh, rapport de maison,*** ខែកុម្ភៈ ឆ្នាំ២០០៥, ទំព័រទី១៣ ។

[៦] សូមអានរបាយការណ៍ និងអនុសាសន៍របស់តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងរបាយការណ៍ស្តីពីសម្បទានដីគោលដៅសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាៈ ទស្សនៈវិស័យខាងសិទ្ធិមនុស្ស, ចុះខែវិច្ឆិការ ២០០៤ ។

[៧] របាយការណ៍ មានចំណងជើង **គិតគូការកាត់បន្ថយភាពក្រីក្រឡើងវិញ ដើម្បីការពារ និងលើកកំពស់សិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា** របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។ គោលដៅខាងសិទ្ធិលើដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ, ចុះខែមេសា ឆ្នាំ២០០៥។

[៨] សូមអានឯកសារ *ការចែករំលែកដោយត្រឹមត្រូវសំរាប់ស្ត្រី* , ទំព័រទី១៦, ខែកុម្ភៈ ២០០៤ របស់ មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិសំរាប់ស្ត្រី, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ និងការអភិវឌ្ឍន៍ដើម្បីអភិវឌ្ឍន៍អន្តរជាតិអង់គ្លេសក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងកិច្ចការនារី។

[៩] ឯកសារដដែល, ទំព័រទី២៧។

[១០] ឯកសារដដែល, ទំព័រទី៣០។